# KhmerPost USA

Advertising: **PA/NJ/NY: (267) 253-3947/ CT: (860) 461-3687**
**MA/RI: (978) 656-8141/ (781) 244-0522**

Vol 06 Issue 120 Dec. 20th- Jan 10th. 2013


**មាតិការឿង** — **ទំព័រ**


១-គណៈកម្មាធិការព្រំដែនប្រទេសកម្ពុជា........................០៥
២-លោក ម៉ម សុណង់ដូត្រូវបាន&លោក ស៊ូបេឌី ជួប...០៦&០៧
៣-សុខភាព និងម្ហូបអាហារ........................................០៨
៤-អ្នកមានទិនអ្នកក្រនៅប្រទេសខ្មែរ.................................០៨
៥- ក្លូបូលវីតណេសរាយការណ៍......................................០១០
៦- សហគមន៍ខ្មែរកោតសរសើរថ្នាក់................................១៦



32 Wamesit St., Lowell, MA 01852. **Phone-Fax (978) 656 8141** www.khmerpost.us





ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ឆ្នាំសកល២០១៣ និងខួបគម្រប់៦ឆ្នាំនៃសារព័ត៌មានខ្មែរផុស សហរដ្ឋអាមេរិក ក្នុងនាមខ្ញុំជានាយករួមនឹងបុគ្គលិកទាំងអស់ សូមថ្លែងអំណរគុណស្មោះអស់ពីដួងចិត្ត ចំពោះគ្រប់បណ្តាក្រុមហ៊ុន សហគ្រាសទាំងអស់ ដែលបានគាំទ្រ និងផ្សព្វផ្សាយពាណិជ្ជកម្ម លើទំព័រកាសែតខ្មែរផុសក្នុងរយៈពេលកន្លងមកនេះ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះមិត្តអ្នកអានសហការរាយការណ៍រួមនឹងមិត្តអ្នកអាន...!

សូមអស់លោក លោកស្រីទទួលនូវសុវត្ថិភាព សុខភាពល្អបរិបូរណ៍ ប្រកបការងាររកស៊ីចំរើន និងទទួលបានជោគជ័យគ្រប់ប្រការ ។ សូមអរគុណ!








# យុទ្ធសាស្ត្រជាមូលដ្ឋាន សំរាប់ការអភិវឌ្ឍន៍ក្រុងខ្មែរឡូវែល

**ដោយបណ្ឌិត សេង លីអង់ ប្រធានក្រុងខ្មែរឡូវែល**

▸ ក្រុងខ្មែរឡូវែលត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាក្រុងឡូវែលឆ្លើយតបទៅនឹងសំណូមពររបស់សហគមន៍ខ្មែរតាមរយៈការស្ទង់មតិសហគមន៍មួយនៅដើមឆ្នាំ២០១០ ។ ការស្ទង់មតិនេះធ្វើឡើងដោយសមាគមខ្មែរក្រុងឡូវែល ក្រោមការដឹកនាំរបស់លោក វង់ រស់ អតីតនាយកប្រតិបត្តិ និងលោក វិទ្ធី អ៊ុង អតីតប្រធានគណៈកម្មការនាយកសមាគមខ្មែរ ។ លោកប្រធានផ្នែកអភិវឌ្ឍន៍សេដ្ឋកិច្ចសមាគមខ្មែរ និងលោក Patrick Murphy សមាជិកក្រុមប្រឹក្សាក្រុង នៅពេលនោះបានដើរធ្វើការស្ទង់មតិសមាជិក **តទៅទំព័រទី ០២**


មន្ត្រីជាន់ខ្ពស់ឡូវែលបើកសម្ពោធក្រុងខ្មែរ



ច្រកទ្វារចូលក្រុងខ្មែរ

# ប្រទេសកម្ពុជាក្នុងតំបន់ខ្យល់ព្យុះ

**ដោយ សុងធុល ហៃណាង់ដេស**



នៅព្រឹត្តិការណ៍ជម្លោះដែលបានកើតឡើងមិនឈប់ឈរនៅមជ្ឈឹមបូព៌ាយើងបានឃើញបញ្ហាថ្មីមួយទៀត គឺមិនចុះសម្រុងគ្នាស្តីពីបូរណភាពទឹកដីរវាងប្រទេសចិនប្រឈមមុខនឹងប្រទេសជិតខាងជាច្រើនទៀតដូចជា ប្រទេសចិន កោះតៃវ៉ាន់ ប្រទេសជប៉ុន ប្រទេសវៀតណាម ប្រទេសប្រ៊ុយណេ ប្រទេស ម៉ាឡេស៊ី ប្រទេសហ្វីលីពីន និងប្រទេសឥណ្ឌា។




បច្ចុប្បន្នភាពប្រទេសចិនកំពុងប្រឈមមុខអំពីបញ្ហាព្រំដែនទឹក និងព្រំដែនគោកជាមួយប្រទេសជាច្រើនរួមមាន: **តទៅទំព័រទី១៧**

## មានអ្វីប្លែក

# ភ្លើងឆេះផ្ទះលោក ម៉ម យីន


លោក ម៉ម យីន និងភរិយា

**ហ្វីឡាដែលហ្វៀ :** លោក ម៉ម យីន ដែលជាព្រឹទ្ធាចារ្យខ្មែរផុសអាយុ៧៨ឆ្នាំជាអ្នកសរសេរជាប្រចាំ ហើយចូលចិត្តធ្វើការផ្សព្វផ្សាយជាទីបំផុតផងនោះ បានទទួលរងគ្រោះដោយសារភ្លើងឆេះផ្ទះកាលពីថ្ងៃទី១២ខែធ្នូ ឆ្នាំ២០១២ វេលាម៉ោង៨ព្រឹក ពុំមាននរណាម្នាក់រងគ្រោះពីអគ្គិភ័យនោះទេ លោក ម៉ម យីន និងភរិយានិយាយថា ភ្លើងផ្តើមនៅបន្ទប់ក្រោយបង្អស់ ដោយការឆេះខ្សែភ្លើងអ្នកជិតខាង គឺលោកស្រែកហ៊ីងបានឮ សំឡេងឆ្លងភ្លើងប្រ៉ស់ៗ **តទៅទំព័រទី.១៦**

## តមកទំព័រទី ១ យុទ្ធសាស្ត្រជាមូលដ្ឋានសំរាប់ការ...

សមាជិការសហគមន៍ ពិសេសពាណិជ្ជករខ្មែរ ស្ទើរតែទាំងអស់នូវគោលគំនិតនៃការបង្កើតក្រុងខ្មែរឡូវែល ។ ជាលទ្ធផលអ្នកចូលរួមក្នុងការស្ទង់មតិបានគាំទ្រយ៉ាងពេញទំហឹងនូវគំនិតផ្តួចផ្តើមបង្កើតមណ្ឌលពាណិជ្ជកម្មពិសេសហៅថា ក្រុងខ្មែរឡូវែល ។ ជោគជ័យនេះមិនអាចកាត់ផ្តាច់ការខិតខំប្រឹងប្រែងរបស់លោក Patrick Murphy និងការគាំទ្រឥតងាករេរបស់លោកទីប្រឹក្សាក្រុង វ៉ាសនា នួន ។ ទន្ទឹមពេលនោះដែរ គណៈកម្មការស្ម័គ្រចិត្តក្រុងខ្មែរឡូវែលមួយក៏ត្រូវបានបង្កើតឡើងឆ្លើយតបទៅនឹងតំរូវការឱ្យមានយន្តការមួយដើម្បីជួយសម្របសម្រួលទំនាក់ទំនងរវាងរដ្ឋការសាលាក្រុង និងសហគមន៍ខ្មែរក្នុងការអនុវតន៍គោលនយោបាយក្រុងខ្មែរនេះ ។

គណៈកម្មការស្ម័គ្រចិត្តនេះមានតួនាទីជាបឋមគឺជួយជំរុញឱ្យមានការសកម្មចូលរួមរបស់សហគមន៍នៅក្នុងដំណើរការនៃការអភិវឌ្ឍន៍ក្រុងខ្មែរលើគ្រប់វិស័យ វិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ។ គណៈកម្មការនេះបច្ចុប្បន្នមានសមាជិកស្ម័គ្រចិត្តចំនួនប្រាំរូបរួមមានលោក បណ្ឌិត គង់ សេង លី ជាប្រធានគណៈកម្មការ, លោក តុលា យុទ្ធ អនុប្រធាន, លោក ខៃ វឌ្ឍា លេខាធិការ, លោក វ៉ង់ រស់ សមាជិក, និងលោក អ៊ុំ សំអាន សមាជិក។ គណៈកម្មការស្វាគមន៍សមាជិកបន្ថែមទៀតពីសហគមន៍ពិសេសពាណិជ្ជករ ឬធុរៈករនៅក្នុងទីក្រុងខ្មែរឡូវែល ។

ដើម្បីអភិវឌ្ឍក្រុងខ្មែរគណៈកម្មការជឿជាក់ថា យើងត្រូវពង្រីកទីផ្សារបច្ចុប្បន្នឱ្យកាន់តែទូលំទូលាយទៅកាន់ពលរដ្ឋអាមេរិកាំងទូទៅថែមទៀត ។ យើងត្រូវមានការលើកទឹកចិត្តឱ្យមានការវិនិយោគទុនឯកជន និងសាធារណៈនៅក្នុងក្រុងខ្មែរ ។ ការបង្កើតក្រុងខ្មែរឡូវែល គឺជាជំហានមួយនៃទិសដៅអភិវឌ្ឍន៍យូរអង្វែង ។

កន្លងមកគណៈកម្មការក្រុងខ្មែរបានសហការជាមួយសាលាក្រុងឡូវែលដើម្បីដាក់បដាសំយុងកំណត់សំគាល់ក្រុងខ្មែរចំនួន៦ផ្ទាំង នៅលើស្តាននៃកំណាត់ផ្លូវ Middlesex Street ។ គណៈកម្មការបាន និងកំពុងបន្តធ្វើការផ្តល់យោបល់ដល់សាលាក្រុងក្នុងការរៀបចំដាក់បដាសំយុងចំនួន១៦ផ្ទាំងបន្ថែមទៀត ព្រមទាំងកៅអីវែង និងធុងសំរាមសំរាប់អនាម័យសាធារណៈ ។ គណៈកម្មការក៏បានពាំនាំសំណើររបស់ពាណិជ្ជករខ្មែរដែលសុំឱ្យមានផ្នប់សំបុត្រសាធារណៈមួយនៅក្នុងមណ្ឌលក្រុងខ្មែរ ដើម្បីបង្កភាពងាយស្រួលក្នុងការផ្ញើរសំបុត្រចេញដោយមិនចាំបាច់ធ្វើដំណើរទៅកាន់ប៉ុស្តិ៍សំបុត្រឡើយ ។ សាលាក្រុងឡូវែលបានដោះស្រាយសំណូមពរនេះដោយបានដាក់ប្រអប់សំបុត្រនៅក្បែរស្ថានីយ៍នគរបាលនៅផ្លូវ Middlesex Street ទល់មុខអាគារប៉ៃលិន Pailin Plaza តាមការស្នើរសុំ ។ ដោយឡែកគណៈកម្មការក្រុងខ្មែរក៏មានគំរោងសាងសង់រូបសំណាកព្រហ្មបាយ័នមុខបួននៅមុំមុខអាគារប៉ៃលិនក្នុងពេលអនាគតផងដែរ ។

នៅមានផែនការច្រើនទៀតដែលត្រូវអនុវត្តន៍បន្ថែមដើម្បីលើកទឹកចិត្តដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងការបង្កើតការងារនៅក្នុងសហគមន៍ ។ ក្រុងខ្មែរត្រូវការនយោបាយពន្ធដារមួយដែលទាក់ទាញ និងលើកទឹកចិត្តដល់ការវិនិយោគទុនឯកជន ។ គោលនយោបាយនេះ គឺការបន្ថយពន្ធលើអចលនៈវត្ថុ(property tax),ការកែសម្រួលច្បាប់ទម្រាប់អោយមានការងាយស្រួលដល់សកម្មភាពធុរៈកិច្ច ឬសកម្មភាពពាណិជ្ជកម្ម ការលើកកំពស់សុវត្ថិភាព និងសន្តិសុខសាធារណៈនៅក្នុងទីក្រុងដើម្បីបង្កបរិយាកាសអំណោយផលដល់ការវិនិយោគនានា ។ ត្រូវបន្ថយពន្ធដារដល់ពាណិជ្ជកម្មដែលមានសស្រាប់ ក៏ដូចជាពាណិជ្ជករដែលមានបំណងមករកស៊ីនៅក្នុងក្រុងខ្មែរ ។ ត្រូវបង្កើនការការពារបាតុភាពអគ្គីភ័យ និងបង្កើនកម្លាំងនគរបាលឱ្យបានគ្រប់គ្រាន់ ដើម្បីធានាសន្តិសុខបរិបូណ៌នៅក្នុងទីក្រុង ។ ត្រូវកែលំអហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ដូចជាដាក់ឱ្យមានភ្លើងគ្រប់គ្រាន់មានចិញ្ចើមថ្នល់ទូលាយងាយស្រួលដល់អ្នកថ្មើរជើង និងបង្កើតគំនូសសុវត្ថិភាពចរាចរសំរាប់ការឆ្លងថ្នល់នៅតាមកន្លែងដែលមានចរាចរមមាញឹក ។ល។ ត្រូវឈូស Snow អោយបានទាន់ពេលវេលា ដើម្បីកាត់បន្ថយការខកខានដល់ការបើកហាងរកស៊ីរបស់ពាណិជ្ជករ ។

យើងត្រូវដាក់ផ្លាកសញ្ញាចរាចរចូលក្រុងខ្មែរអោយបានច្រើនកន្លែងតាមដែលអាចធ្វើទៅបាន ។ ផ្លាកសញ្ញាចរាចរទាំងនេះ គួរត្រូវដាក់តាមច្រកចេញចូលសំខាន់ៗ ដូចជា Lowell Connector ជាដើម ។ បើអាចធ្វើទៅបានត្រូវដាក់ផ្លាកផ្សាយពាណិជ្ជកម្មក្រុងខ្មែរនៅទីកន្លែងដែលអាចមើលឃើញពីផ្លូវជាតិសំខាន់ៗ ដូចជា I-495, ផ្លូវលេខ ៣ និងទីប្រជុំជនទីក្រុងឡូវែល (Downtown Lowell) ។ ជាងនេះទៀត □ត្រូវបង្កើតឱ្យមាន Bus Stops នៅកន្លែងចរាចរច្រើន និងបង្កើតឱ្យមានផ្លូវរថយន្ត Bus ដែលភ្ជាប់ទីក្រុងខ្មែរទៅទីប្រជុំជនក្រុងឡូវែល (Downtown Lowell) ។

ក្រៅពីគោលយោបាយបន្ថយពន្ធ និងកែលំអរហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់យើងអាចលើកកំពស់ការអភិវឌ្ឍន៍សេដ្ឋកិច្ចតាមរយៈការកែសម្រួលគោលនយោបាយតំបន់ពាណិជ្ជកម្ម ឬ Zoning ។ ជំរុញអាជ្ញាធរមានកំណត់តំបន់ឱ្យពិនិតឡើងវិញនូវគោលនយោបានតំបន់ពាណិជ្ជកម្ម ដើម្បីលើកទឹកចិត្តឱ្យបង្កើតថែមទៀតនូវតំបន់ពាណិជ្ជកម្មចំរុះ។ ការកែសម្រួលនេះអាចលើកទឹកចិត្តឱ្យម្ចាស់អាគារច្រើនខ្នងអាចប្រើប្រាស់អាគាររបស់ខ្លួនឱ្យអស់លទ្ធភាពដោយមួយផ្នែកសំរាប់ជាកន្លែងរស់នៅ និងមួយផ្នែកទៀតសំរាប់កន្លែងរកស៊ី ។

ដើម្បីឱ្យអាជ្ញាធរមានសាលាក្រុងសម្រេច និងដោះស្រាយតំរូវការអភិវឌ្ឍន៍ទាំងនេះ ទាមទារឱ្យមានការប្រមូលផ្តុំ និងចាត់តាំងសហគមន៍ទាំងមូលដើម្បីធ្វើសំណូមពររួមទៅក្រុមប្រឹក្សាក្រុងឡូវែល ។ យើងចាំបាច់ត្រូវសហការជិតស្និទ្ធជាមួយសមាជិកក្រុមប្រឹក្សាក្រុងលោក វ៉ាសនា នួន, លោកចៅហ្វាយក្រុង Patrick Murphy, និងសមាជិក-សមាជិកា ក្រុមប្រឹក្សាក្រុងឯទៀតៗ ដើម្បីអនុម័តថវិការគ្រប់គ្រាន់សំរាប់អនុវត្តគោលនយោបាយដែលអំណោយផលដល់ការអភិវឌ្ឍន៍ទីក្រុងខ្មែរឡូវែលដូចជំរាបជូនត្រួសៗខាងលើ ៕


គណកម្មាធិកាអភិវឌ្ឍន៍ក្រុងខ្មែរឡូវែលដឹកនាំដោយ បណ្ឌិត សេងលី គង់


ភ្ញៀវមកស្តាប់ការណែនាំពីការបង្កើតក្រុងខ្មែរ


តាទ្រីក ម័រហ្វី ទើបឈ្នោះជាចៅហ្វាយក្រុងឡូវែល និង សេងលី គង់ ប្រធានក្រុងខ្មែរ ណែនាំពីអត្ថប្រយោជន៍នៃតំបន់ដែលមានឈ្មោះថា ក្រុងខ្មែរ

តមកពីទំព័រទី ៩

## ភ្លើងឆេះផ្ទះលោក ម៉ម យីន

នៅពេលបណ្តើរវែ្តពេលព្រឹកស្រាប់តែភ្លើងឆាបឆេះនៅពេលបន្តិចក្រោយមក។ ភ្លើងបានឆេះចូលផ្ទះបាយបណ្តាលឱ្យផ្សែងឆ្លងចូលបន្ទប់ទទួលភ្ញៀវនឹងបន្ទប់ដេក...ទាំងអស់គ្នា( មនុស្ស ៥នាក់) បានគេចចេញរកកន្លែងសុវត្ថិភាព ទើបក្រុមពន្លត់ភ្លើងមកដល់ ហើយធ្វើការយ៉ាងប្រសិទ្ធភាពទប់ស្កាត់ភ្លើងបាននៅពេលបន្តិចមក។ ផ្ទះលោក ម៉ម យីន មានការខូចខាតផ្នែកខាងក្រោយជាដំណំ រីឯដំបូងបានត្រូវឆេះបីកន្លែង ដើម្បីទម្លាយផ្សែងឱ្យចេញ ដើម្បីសង្គ្រោះ។ កូននឹងចៅពីរគ្រួសារបានត្រូវបញ្ជូនទៅស្នាក់អាស្រ័យនៅកន្លែងពីរផ្សេងគ្នា គឺគ្រួសារលោក ម៉ម យីន នឹងគ្រួសារជាង វ៉ាត ជាកូន ។ ជាង វ៉ាត គឺជាម្ចាស់រោងជួលជុលរថយន្តដែលផ្តល់ការថែទាំរថយន្តខ្មែរផុសយ៉ាងជិតដល់ ។

ពេលនេះគ្រួសារទាំងពីរមានចិត្តទូលំទូលាយតែមានធនធានតូចទាបត្រូវការការគាំទ្រពីបិត្តភ័ត្រ្តចឹងសាធារណជន សូមលោកអ្នកផ្តល់ការគាំទ្រដល់គ្រួសារស្លូតត្រង់ទាំងពីរដោយសទ្ធា។ ទូរស័ព្ទលោក ម៉ម យីន ២១៥ ២០០ ៣៨១០ ៕

## យុវជនរស្មី មុនី យិន ត្រៀមមានអនាគតល្អ

**ហ្វីឡាដែលហ្វៀ :** លោក ម៉ម យីន នឹងភរិយារងគ្រោះដោយអគ្គិភ័យមែនតែក៏មានដំណឹងល្អខ្លះ មកជួយលំអគ្រួសារនេះដែរ។ កូនប្រុសឈ្មោះរស្មីមុនី យីន អាយុ២០ឆ្នាំទើបនឹងត្រឡប់មកពីបំពេញការសិក្សា៦ប្រទេសនៅយូរ៉ុប ខាងផ្នែកអប់រំកុមារ។ រស្មីមុនី ជានិស្សិតឆ្នាំទី៣នៅមហាវិទ្យា



រដ្ឋជេនស៊ីវេនាខាងផ្នែកអប់រំសង្គមជាកូនភ្លោះប្រុសម្នាក់ក្នុងចំណោមបីដែលមានអាយុដំណាលគ្នា ហើយក៏នៅរៀនមហាវិទ្យាល័យទាំងអស់គ្នាក្នុងជំនាញខុសៗគ្នា។

រស្មី មុនី ទើបនឹងបញ្ចប់ការសិក្សាជំនាញអប់រំនៅប្រទេស៦នៃយូរ៉ុបរបស់កម្មវិធី Danish Turkish Education Child Development ហើយក៏មានបំណងត្រឡប់ទៅធ្វើការជាបន្តនៅដំដែលនោះវិញ កន្លែងដែលខ្លួនគាប់ចិត្តនៅពេលរៀនចប់សព្វគ្រប់ ៕

## មរណភាពនៃ មេចលនា "ខ្មែរសេរី" ឡឹក សំអឿន

**ឡូវែល :** លោក ឡឹក សំអឿន បានចូលមរណភាពដោយជរាភាពក្នុងជន្មាយុ៨៥ឆ្នាំកាលពីថ្ងៃអង្គារទី១៨ខែធ្នូ ២០១២ នៅមន្ទីរពេទ្យធំនៃក្រុងឡូវែលរដ្ឋម៉ាសាឈូសសែត។

លោកជាអ្នកតស៊ូប្រឆាំងរបបសម្តេច ស៊ីហនុ ដ៏ល្បីល្បាញម្នាក់បន្ទាប់ពីលោក សឺង ង៉ុកថាញ់ ក្រោមឧទ្ទិសនាម "ផ្កាយព្រឹក" លោកបានសរសេរជីវប្រវត្តិនឹងប្រវត្តិសាស្ត្រទាក់ទងនឹងជីវិតរបស់លោកក្នុងសៀវភៅ"ខ្មែរអ្នកជាតិនិយាយ"កាលពីឆ្នាំ២០០៥ ហើយសន្យាថា នឹងសរសេរសៀវភៅមួយទៀតឈ្មោះ



ថា"សាធារណរដ្ឋខ្មែរ"តែមកទល់ពេលនេះសៀវភៅនេះពុំទាន់បោះពុម្ពនៅឡើយទេ ។ លោក ឡឹក សំអឿន បានលាចាកចោលភរិយា នាម មករា និងកូនស្រីឈ្មោះ បូរីណេត អាយុ ៤០ឆ្នាំ នឹងកូនប្រុសឈ្មោះ ខេមរា អាយុ៣១ឆ្នាំដោយអាឡោះអាល័យ ។

លោក ស្រី មករា ឡឹក ជាភរិយាបានឱ្យដំណឹងថា ពិធីបុណ្យបូជាសព និងធ្វើនៅវត្តលើត្រែរតនារាម ថ្ងៃទី២៨ នឹង២៩ធ្នូ ឆ្នាំ២០១២ខាងមុខនេះ ។

សូមវិញ្ញាណក្ខន្ធរបស់លោកបានជួបនឹងសុគតិភពកុំបីឃ្លាតឡើយ ៕

## ភិក្ខុ លួន សាវ៉ាត ទទួលប័ណ្ណសរសើរពីទីក្រុងលីន



**រាយការណ៍ ដោយៈ សុផាណា សូ**

**ក្រុងលីន :** កាលពីថ្ងៃសៅរ៍ទី០៨ ខែធ្នូ ឆ្នាំ១២ កន្លងទៅនេះ ភិក្ខុ លួន សាវ៉ាត សកម្មជនការពារសិទ្ធិមនុស្សកម្ពុជាដែលនិមន្តមកពីខេត្តសៀមរាប



ត្រូវបានចៅហ្វាយក្រុងលីន Jundith Flanagan Kennedy និង Cuty Councilor-at-Large Hong L.net

តទៅទំព័រទី ១៦


# GATEWAY FAMILY DENTAL

NOW OPENED AT GATEWAY CENTER II (978) 455-5044

151 WARREN STREET, SUITE 120 LOWELL, MA 01852 (Same building as Social Security/near the courthouse)






**DR. SERENA B. CHUOP**

Dr. Serena B. Chuop was born in Cambodia. She received her Bachelor of Science from Boston University and went on to graduate from Boston University Goldman School of Dental Medicine in the year 2000. For over 10 years, she has been in private practices providing all aspects of General Dentistry. Dr. Chuop has opened a brand new state of the art dental practice that includes digital x-ray, paperless patient chart system, and brand new dental equipments.

**WE PROVIDE ALL SERVICES INCLUDING: យើងផ្តល់នូវសេវាដូចខាងក្រោមនេះ**

- CLEANING
- FILLINGS
- BONDINGS
- COSMETIC DENTISTRY
- CROWNS/BRIDGES
- DENTURES
- IMPLANTS
- EXTRACTIONS
- TEETH WHITENING
- VENEERS
- EMERGENCY DENTAL TREATMENT
- ROOT CANAL TREATMENT
- DENTAL SERVICES TO CHILDREN

- សំអាតធ្មេញ
- បំពេញធ្មេញប្រហោង
- ថ្នាំសំរាប់ការពារធ្មេញ
- ធ្មេញពាក់ជុំនួសធ្មេញដែលបាក់
- ក្រាសធ្មេញពាក់
- ដាំធ្មេញតាមរន្ធធ្មេញចាស់
- ដកធ្មេញ
- ធ្វើធ្មេញឱ្យសស្អាត
- វ៉ែរនីស្រោបធ្មេញ
- ព្យាបាល និងការពារធ្មេញជាទៀងទាត់
- ព្យាបាល ឫសថ្គាមធ្មេញ
- សេវាព្យាបាលសំរាប់កុមារ

www.gatewayfamilydental.com

**MOST DENTAL INSURANCES ACCEPTED**
**INCLUDING MASSHEALTH FOR KIDS**
**FINANCING AVALIABLE**
**យើងទទួលនូវគ្រប់ អ៊ិន ស៊ូរិន**
**Masshealth for Kids**
**យើងសំរួលការបង់ថ្លៃព្យាបាលប្រចាំខែ**
**CALL FOR YOUR FREE CONSULTATION**
**(978) 455-5044**

# គណៈកម្មាធិការព្រំដែនកម្ពុជា

សមាគម មិនជាប់ពាក់ព័ន្ធ នឹង គណៈបក្ស នយោបាយ

Comité des Frontières du Cambodge ( C F C ) — Cambodia's Border Committee ( C B C )

ASSOCIATION NON APPARENTEE AU PARTI POLITIQUE ASSOCIATION UNAFFILIATED TO A POLITICAL PARTY

## គណកម្មាធិការព្រំដែនកម្ពុជាប្រទេសបារាំង និងក្នុងពិភពលោក

### បារីសថ្ងៃទី ២០ តុលា ឆ្នាំ២០១២

### ផលវិបាកនៃសន្ធិសញ្ញាដែលបានចុះជាមួយប្រទេសវៀតណាម

ក្នុងឆ្នាំ១៩៧៩-១៩៨២-១៩៨៣-១៩៨៥-២០០៥



សៀន ប៉េងសែ

ក/ សន្ធិសញ្ញាចុះថ្ងៃទី ១៨ កុម្ភៈ ១៩៧៩ (តពីលេខមុន)

(តពីលេខមុន)

**ជាពាក្យបញ្ចប់ :**

១-ត្រូវមើលសេចក្ដីរាយការណ៍របស់នាយសេនាធិការកងយោធពលខេមរភូមិន្ទ លោក កែ គីមយ៉ាន ផ្ញើទៅលោក ហ៊ុន សែន ដែលលោកបានធ្វើក្នុងខែសីហា ឆ្នាំ ១៩៩៩ (D2 Gl Ké Kim Yan) ស្ដីពីការទន្រ្ទានទឹកដីដោយយួនមកលើប្រទេសកម្ពុជា ពាក្យត្អូញត្អែររបស់ប្រជាពលរដ្ឋដែលរស់នៅតាមតំបន់ព្រំដែនលើកឡើងដោយលោក ម៉ម សូណង់ដូ ក្នុងឆ្នាំ២០០១ (D3 Sonando) និងរបាយការណ៍ផ្សេងៗទៀតពីប្រជាពលរដ្ឋ...

២-នៅថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០០២ គណកម្មាធិការព្រំដែនកម្ពុជាយើងបានផ្ញើលិខិតមួយទៅជូនលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ដើម្បីទាមទារឱ្យដាក់សន្ធិសញ្ញា និងកិច្ចព្រមព្រៀងខុសច្បាប់ និងមិនស្មើភាពគ្នាដែលបានធ្វើក្នុងអំឡុងឆ្នាំ១៩៨០ រវាងសាធារណរដ្ឋសង្គមនិយមវៀតណាម និងសាធារណរដ្ឋប្រជាមានិតកម្ពុជាទាំងអស់នេះ ជាមោឃភាពស្របទៅតាមបទបញ្ញត្តិនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងបារីសស្ដីពីប្រទេសកម្ពុជាថ្ងៃទី២៣ ខែតុលា ឆ្នាំ ១៩៩១ ។

៣-នៅក្នុងឆ្នាំ២០០៥ បន្ទាប់ពីការយកព័ត៌មានរបស់កាសែតប៉ុកំបូដស្វារ ផ្សាយថ្ងៃទី ២៧ ខែ កក្កដា ស្ដីពីការរំលោភដោយពួកយួននៅក្នុងខេត្តស្វាយរៀងមក ៤ខែមុនការចុះហត្ថលេខាលើសន្ធិសញ្ញាឆ្នាំ ២០០៥ ព្រះករុណានរោត្ដម សីហនុ បានធ្វើកំណត់សំគាល់យ៉ាងដូចនេះ: "ការប្របិចប្របោចទឹកដីនៅតែបន្ត...ទុក្ខវេទនាមិនអាចរ៉ាយរ៉ាប់បានរបស់ពលរដ្ឋតូចតាចយើង..." ប៉ុន្តែសព្វថ្ងៃនេះ ខ្ញុំមិនអាចធ្វើអ្វីបានឡើយ... (D4Sihanouk) ។ អញ្ចឹងប្រជាពលរដ្ឋឥតបានសាកល្បងការពារបូរណភាពទឹកដីរបស់ប្រទេសទេ ឬទេ?

៤-ក្នុងប្រទេសកម្ពុជា សតវត្សរ៍ទី២០ លោក ប៉ែន សុវណ្ណ អតីតអគ្គលេខាធិការបក្ស និងជាអតីតរដ្ឋមន្ត្រីទី១នៃសាធារណរដ្ឋប្រជាមានិតបានថ្កោលទោសយ៉ាងច្បាស់ពី "ការរំលោភដោយយួនលើសន្ធិសញ្ញាសន្តិភាព មិត្តភាព និងសហប្រតិបត្តិការណ៍" ដែលពួកនេះបាន ចុះហត្ថលេខានៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ ១៩៧៩ : ពួកវាបានចាប់ផ្ដើមពីការបង្ខិតបង្គោលព្រំដែនចូលមកក្នុងប្រទេសកម្ពុជានៅភ្នំដិន (ខេត្តតាកែវ) នៅទួលក្រសាំង (ស្វាយរៀង) មេមត់ (កំពង់ចាម)... និងការបញ្ជូនពួកអាណានិគមជនវាជាច្រើនលើសលុបឥតឈប់ឈរចូលមកក្នុងប្រទេសយើងដោយគ្មាន ការអនុញ្ញាតពីយើងនោះឡើយ" ។

នេះជាបញ្ហាស្លាប់រស់ដែលជាភារៈរបស់យើងជាពិសេស ។ យើងត្រូវិះរកដំណោះស្រាយឱ្យបាន ។ មហាអំណាចបរទេសគេមិនអាចនឹងធ្វើអ្វីជំនួសយើងបាននោះឡើយ ។

គឺយើងទេ ដែលត្រូវតែយល់ត្រូវតែដឹង ។ យើងមិនអាចទុកស្ថានភាពនេះឱ្យនៅទៅមុខទៀតជាអនន្តដែលនឹងនាំឱ្យទាំងទឹកដីទាំងអត្តសញ្ញាណរបស់យើងបាត់បង់ទៅជាអវសាននោះឡើយ ៕




បណ្ឌិត ឡាវ ម៉ុងហៃ និងលោក អ៊ូ វិរៈ ដែលធ្លាប់មានទស្សនៈការពារផលប្រយោជន៍ខ្មែរ បានស្នើប្រជាជាតិឱ្យឈប់គិតគូរទាមទារកោះត្រល់ និងកម្ពុជាក្រោមពីព្រោះជារបស់វៀតណាមយូរណាស់ទៅហើយ


Neighborhood Health Plan of Rhode Island

តើលោកអ្នកត្រូវការៗធានារ៉ាប់រងផ្នែកសុខភាពឬ?

សូមទូរស័ព្ទទាក់ទងក្រសួងណេបើរហ៊ូដថ្ងៃនេះ

Need Health Insurance?

Call Neighborhood Today

1-401-459-6171

www.nhpri.org



MARCOTTE LAW FIRM

ក្រុមហ៊ុនមេធាវី Marcotte

45 MERRIMACK STREET

LOWELL, MASSACHUSETTS

(978) 458-1229

- សេចក្ដីគ្រោះថ្នាក់ដល់រូបរាងកាយ
- ពិការភាពដោយសន្តិសុខសង្គម
- គ្រោះថ្នាក់ចរាចរណ៍
- បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
- គ្រោះថ្នាក់នៅការដ្ឋាន
- ច្បាប់គ្រួសារ និងលែងប្ដីប្រពន្ធ
- បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍

- Personal Injury
- Family Law & Divorce
- Disability
- Traffic Accidents
- Sex & Drug Crimes, OUI
- Work Accidents

មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទមកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ

(978) 458-1229

www.marcottelawfirm.com

ឌី ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសែតអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌី ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ ព្រហស្បត្តិ៍ ទី០៦ ខែធ្នូ ឆ្នាំ២០១២

# លោក ម៉ម សូណង់ដូ ត្រូវបានបដិសេធមិនឱ្យនៅក្រៅឃុំបណ្ដោះអាសន្ន

**ខេមបូឌាដេលី**

សាលាឧទ្ធរណ៍កាលពីថ្ងៃសុក្របានបដិសេធសំណើរសុំនៅក្រៅឃុំបណ្ដោះអាសន្នរបស់លោក ម៉ម សូណង់ដូ ម្ចាស់ស្ថានីយ៍វិទ្យុសម្បុកឃ្មុំ និងជាអ្នករិះគន់រដ្ឋាភិបាល ដែលកំពុងជាប់ពន្ធនាគារ អំឡុងការបើកសវនាការដ៏បន្ទាន់មួយ ដោយមានអ្នកគាំទ្ររបស់លោក ម៉ម សូណង់ដូ រាប់រយនាក់ បាននាំគ្នាដើរក្បួនទៅកាន់ការិយាល័យឧត្ដមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ក្នុងរាជធានីភ្នំពេញ ដើម្បីអំពាវនាវសុំជំនួយពីលោក សុរិយា ស៊ូបេឌី (Surya Subedi) ប្រេសិតពិសេសអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា ។

ម្ចាស់ស្ថានីយ៍វិទ្យុសម្បុកឃ្មុំអាយុ៧២ឆ្នាំរូបនេះ សព្វថ្ងៃកំពុងជាប់ពន្ធនាគាររយៈពេល២០ឆ្នាំ ពីបទពាក់ព័ន្ធនឹងការញុះញង់ឱ្យបង្កើតចលនាអបគមន៍នៅក្នុងខេត្តក្រចេះ កាលពីខែឧសភា ដែលគេចាត់ទុកថា ជាការចោទប្រកាន់មួយពាក់ព័ន្ធនឹងបញ្ហានយោបាយ ។

លោក ឃុន លាងម៉េង ប្រធានក្រុមប្រឹក្សាជំនុំជម្រះបានមានប្រសាសន៍ថា នៅពេលបញ្ចប់សវនាការរយៈពេល៤០នាទីថា "តុលាការមិនអាចដោះលែងលោក ម៉ម សូណង់ដូ ឱ្យនៅក្រៅឃុំបណ្ដោះអាសន្នបានឡើយ" ។

លោក ចៅក្រមលាងម៉េង បានមានប្រសាសន៍ ដោយពន្យល់ពីការសម្រេចបដិសេធមិនផ្ដល់ការដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្នរបស់លោកថា "តុលាការខ្លាចក្រែងលោកនិងដាក់សម្ពាធលើសាក្សី ហើយបង្កឱ្យខូចសណ្ដាប់ធ្នាប់សាធារណៈ" ។

លោក ហ៊ាន រិទ្ធិ ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ បានមានប្រសាសន៍ថា ដោយសារតែលោកម៉ម សូណង់ដូ មានសញ្ជាតិពីរគឺ សញ្ជាតិខ្មែរ និងសញ្ជាតិបារាំង ហេតុដូច្នេះគេមិនអាចដោះលែងលោកឱ្យនៅក្រៅឃុំបណ្ដោះអាសន្នបានឡើយ ពីព្រោះលោកអាចភៀសខ្លួនទៅកាន់ប្រទេសបារាំង ។

លោក ម៉ម សូណង់ដូ ដែលកំពុងមានបញ្ហាសុខភាពចាប់តាំងពីលោកជាប់ពន្ធនាគារកាលពីខែកក្កដាមកបានលើកឡើងម្ដងទៀតពីភាពគ្មានទោសរបស់លោក ចំពោះមុខចៅក្រមអំឡុងពេលបើកសវនាការដ៏ខ្លី ហើយបានអះអាងម្ដងទៀតថា លោកមិនបាននៅក្នុងប្រទេសកម្ពុជាឡើយ ពេលចលនាអបគមន៍បានកើតនោះ ។

លោក ម៉ម សូណង់ដូ បានប្រាប់តុលាការថា "ករណីនេះ កើតឡើងនៅពេលខ្ញុំកំពុងនៅក្នុងប្រទេសបារាំង ហើយខ្ញុំមិនបានដឹងអ្វីដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាឡើយ ។ ប្រសិនបើខ្ញុំបានធ្វើខុសមែននោះអីចឹងខ្ញុំនិងមិនវិលត្រឡប់មកកាន់ប្រទេសកម្ពុជាឡើយ" ។

លោកបានបន្តថា "ខ្ញុំបានជាប់ពន្ធនាគាររយៈពេល៥ខែ ហើយក្នុងមួយខែៗខ្ញុំបានស្រក់ទំងន់អស់មួយគីឡូក្រាម" ។

លោក ស សុវណ្ណ មេធាវីរបស់លោក ម៉ម សូណង់ដូ បានអំពាវនាវឱ្យតុលាការពិចារណាអំពីការឃុំឃាំងកូនក្តីរបស់ខ្លួននៅក្នុងផ្ទះវិញ ឬក៏តុលាការអាចចេញសេចក្តីបង្គាប់មិនឱ្យលោកទាក់ទងជាមួយសាធារណជនក៏បាន ។

លោក សុវណ្ណ ថ្លែងថា "សូមដោះលែងលោកឱ្យនៅក្រៅឃុំឬហាមលោកកុំឱ្យចាក់ចេញក្រៅផ្ទះរបស់លោក ឬក៏ហាមលោកមិនជួបជាមួយនឹងអ្នកព័ត៌មានក៏បាន" ។

ទាំងលោក ម៉ម សូណង់ដូ និងភរិយារបស់លោកសុទ្ធតែបានលើកឡើងថា ពួកគេនឹងប្តឹងសាទុកទៅតុលាការកំពូល ។

នៅខាងក្រៅសាលាឧទ្ធរណ៍អ្នកគាំទ្រជាង ៣០០នាក់ ដែលពាក់អាវយឺត និងពាក់មួកដែលមានរូបលោក ម៉ម សូណង់ដូ បានតវ៉ាសុំឱ្យដោះរូបលោក ។ នៅពេលបានឮថា លោកមិនត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្ននោះ អ្នកតវ៉ាជាច្រើនបាននាំគ្នាស្រក់ទឹកភ្នែក ។

លោកស្រី ស៊ឹម ឡាយ អាយុ៥៣ បាននិយាយថា អ្នកស្រីលែងជឿលើប្រព័ន្ធតុលាការក្នុងប្រទេសកម្ពុជាហើយ ។

អ្នកស្រី ស៊ឹម ឡាយ បាននិយាយទាំងខ្សឹបខ្សួលថា "ខ្ញុំខឹងយ៉ាងខ្លាំងចំពោះការបដិសេធមិនព្រមដោះលែងលោក ម៉ម សូណង់ដូ ឱ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន ប៉ុន្តែលទ្ធផលនេះ នឹងធ្វើឱ្យខ្ញុំតវ៉ាកាន់តែខ្លាំង" ។

បន្ទាប់ពីលោកម៉ម សូណង់ដូ ត្រូវនាំទៅកាន់ពន្ធនាគារព្រៃសវិញ អ្នកគាំទ្ររបស់លោកជាច្រើនរបស់លោកបានដើរក្បួនទៅកាន់ការិយាល័យរបស់ឧត្តមស្នងការអង្គការសហប្រជាជាតិតាមបណ្ដោយផ្លូវលេខ៣០២ ដើម្បីអំពាវនាវសុំជំនួយពីលោក សុរិយា ស៊ូបេឌី ដោយមាននគរបាលនិងកងរាជអាវុធហត្ថរាប់រយនាក់តាមរាំងពីក្រោយពួកគេ ។

មួយរំពេចក្រោយមកលោក សុរិយា ស៊ូបេឌី បានមកដល់ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ហើយបានសុំអភ័យទោសដល់អ្នកតវ៉ារាប់រយនាក់ ដែលមានកំហឹងនៅតាមផ្លូវ ដោយសារតែលោកមិនបានចូលរួមក្នុងសវនាការរបស់លោក ម៉ម សូណង់ដូ ដោយផ្ទាល់នោះ ។

លោក សុរិយា ស៊ូបេឌី មានប្រសាសន៍ថា សេចក្ដីសម្រេចរបស់សាលាឧទ្ធរណ៍ គឺពោរពេញទៅដោយចម្ងល់ ។ តទៅទំព័រទី១៤

# Sonando Denied Bail, Court Cites "Disorder"

**The Cambodia Daily**

The Court of Appeal on Friday denied bail to imprisoned radio station owner and government critic Mam Sonando during a rapid-fire hearing, while hundreds of Mr.Sonando's supporters marched to the U.N.'s office of the High Commissioner for Human Right in Phnom Penh to appeal for help from U.N. envoy to Cambodia Surya Subedi.

The 72-years-old radio Station owner currently serving a 20-year jail sentence for his alleged involvement in stirring up a so-called uprising in Kratie province in May, a charge that has been widely derided as politically motivated.

"The Court does not agree to release Man Sonando, 72, on bail," presiding Judge Khun Leang Meng said at the end of the 40 minute session.

"The court is afraid that he will be able to put pressure on witnesses and cause public disorder," Judge Leang Meng said by way of an explanation for his decision to deny bail.

Hean Rith, the Appeal Court's prosecutor, said that because Mr. Sonando has dual nationality-Cambodian and French-he should not be released on bail because he might flee to France.

Mr. Sonando-who has faced a host of health problems since he was jailed in July-reiterated his innocence to the judges during his brief heading, pointing out, once again, that he was not even in the country when the so-called uprising took place.

"This case occurred while I was in France and I don't know what happened," Mr. Sonando told the court. "If I did wrong, I would not have returned to Cambodia," he said.

"I have been imprisoned for five months and for each month, I have lost a kilogram," he added.

Mr. Sonando's lawyer, Sar Sovann, appealed to the court to consider house arrest for his elderly client, adding that the court could also impose a gag order on the popular radio stationer owner.

"Please release him on bail, even if he is not allowed to go out side his house or to meet journalists," Mr. Sovann said.

Both he and Mr. Sonando's wife said they would now appeal to the Supreme Court.

Outside the court of Appeal, more than 300 spporters-dressed in T-shirts and hats bearing Mr. Sonando's face-protested for his release. When they heard that he was denied bail, several burst into tears.

Sim Lay, 53, said that she has lost hope in the judicial system.

"I am very angry with the court denying Mam Sonando bail, but this result will make me stronger in my protests," Ms. Lay said, speaking between sobs.

After Mr. Sonando was driven back to Prey Sar prison, his suporters marched to the U.N.'s Office of the High Commisioner for Human Rights on Street 302-with hundreds of police and military police officers tailing them-to appeal for help from Surya Subedi, the human rights envoy to Cambodia.

Shortly after, Mr. Subedi arrived at the office and apologized to the hundreds-strong crowd in the street for not being able to attend Mr. Sonando's hearing in person. The decision of the Appeal Court, Mr. Subedi said, was questionable.

"The decision made by the court this morning is puzzling to me. At his age and health, I would have expected that the court would grant him bail," Mr. Subedi said, using a loudspeaker to address the crowd gathered outside the U.N. office.

Mr. Subedi visited Mr. Sonando in prison on Wednesday and spendt an hour talking to him about his case and his conditions in jail.

Human rights groups also expressed disappiontment with the decision to deny bail and said that the court's stated reasons were "baselss."

"[B]y refusing Mam Sonando bail and continuing the detention of the [72-years-old] journalist nad human rights defender, the judicial system showed itself to be politically pliant," local rights group Adhoc said in a statement.

"CHRAC [The Cambodian Human Rghts Action Committee] is of the view that [the desision] lacks legal reasoning in failing to consider the submissions from Mr. Sonando's lawyer," the group said a statement.

"We are concerned a bout the political interference with the judicial ruling of this case," CHRAC added.

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងបកប្រែសម្រួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ ព្រហស្បតិ៍ ទី០៦ ខែធ្នូ ឆ្នាំ២០១២

## លោក ស៊ូបេឌី ជួបជាមួយអ្នកគាំទ្រលោក ម៉ម សូណង់ដូ តាមផ្លូវនិយាយពីបញ្ហាសិទ្ធិមនុស្ស

**ខេមបូឌា ដេលី**

មុនពេលធ្វើសន្និសីទសារព័ត៌មានលើកចុងក្រោយនៃដំណើរទស្សនកិច្ចរបស់ខ្លួនកាលពីថ្ងៃសុក្រលោក សុរិយា ស៊ូបេឌី (Surya Subedi) ប្រេសិតពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា បានជួបជាមួយប្រជាពលរដ្ឋជាង៣០០នាក់ ដែលជាអ្នកគាំទ្រលោក ម៉ម សូណង់ដូ ម្ចាស់ស្ថានីយ៍វិទ្យុសម្បុកឃ្មុំ ដោយឥតគ្រោងទុកនៅលើកំណាត់ផ្លូវលេខ៣០២ ក្នុងរាជធានីភ្នំពេញ ហើយសន្យាថា នឹងតាមឃ្លាំមើលរឿងក្តីនេះ ដោយយកចិត្តទុកដាក់បំផុត។

បណ្តាលអ្នកគាំទ្រលោក ម៉ម សូណង់ដូ បានដើរក្បួនពីសាលាឧទ្ធរណ៍ភ្លាមៗទៅកាន់ការិយាល័យសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ដើម្បីស្វែងរកជំនួយពីលោក ស៊ូបេឌី បន្ទាប់ពីលោកម៉ម សូណង់ដូ ត្រូវបានតុលាការសម្រេចច្រានចោលសំណើរសុំនៅក្រៅឃុំជាបណ្តោះអាសន្នកាលពីថ្ងៃសុក្រ។

ដោយត្រូវសាលាដំបូងផ្តន្ទាទោសឱ្យជាប់ពន្ធនាគាររយៈពេល២០ឆ្នាំ កាលពីខែតុលាដោយចោទប្រកាន់ ដែលមជ្ឈដ្ឋានជាច្រើនចាត់ទុកថា ជារឿងនយោបាយនោះ លោកបារ៉ាក់ អូបាម៉ា (Barak Obama) ប្រធានាធិបតីសហរដ្ឋអាមេរិក ធ្លាប់មានប្រសាសន៍សំដៅដល់លោក ម៉ម សូណង់ដូ អាយុ៧២ឆ្នាំថា ជាអ្នកទោសនយោបាយ។

ថ្លែងទៅកាន់អ្នកគាំទ្រលោក ម៉ម សូណង់ដូ លោក ស៊ូបេឌី បានមានប្រសាសន៍ថា លោកមានការសោកស្តាយណាស់ ដែលលោកមិនអាចចូលរួមក្នុងសវនាការដោយផ្ទាល់បាន ហើយលោកបានចាត់ទុកសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ថា "ពិបាកនឹងយល់"។

លោក ស៊ូបេឌី បានមានប្រសាសន៍ទៅកាន់អ្នកទាំងនេះដែលបានស្វាគមន៍ការលើកឡើងរបស់ដោយការទះដៃ និងស្រែកហ៊ោកញ្ជ្រៀវថា "ខ្ញុំព្រួយបារម្ភជាខ្លាំងណាស់ចំពោះស្ថានការណ៍នេះ ហើយខ្ញុំបានផ្តល់អនុសាសន៍ដល់រដ្ឋាភិបាលរួចហើយ"។ លោកបានសន្យាថា លោកនឹងបន្តតាមឃ្លាំមើលរឿងក្តីរបស់លោក ម៉ម សូណង់ដូ។

លោក ស៊ូបេឌី បានប្រាប់អ្នកគាំទ្រនេះថា "សូមអរគុណបងប្អូនខ្លាំងដែលមកជួបខ្ញុំ ហើយខ្ញុំសូមកោតសរសើរចំពោះការបង្ហាញទឹកចិត្តរបស់បងប្អូន"។

ក្រោយមកនៅសន្និសីទសារព័ត៌មានមួយមុនពេលលោកចាកចេញពីប្រទេសកម្ពុជា លោក ស៊ូបេឌី បានមានប្រសាសន៍ថា បញ្ហាសិទ្ធិមនុស្ស វប្បធម៌និទណ្ឌភាព និងការធ្លាក់ចុះខាងសេរីភាពបញ្ចេញមតិ គឺបញ្ហាធំៗដែលប្រទេសកម្ពុជាកំពុងតែជួបប្រទះ។

ដោយចាត់ទុកកម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលទើបតែចាប់ផ្តើមក្នុងពេលថ្មីៗនេះ ថាជា "ការវិឌ្ឍគួរឱ្យស្វាគមន៍" ដែលត្រូវអនុវត្តន៍ចាប់តាំងពីដំណើរទស្សនកិច្ចលើកចុងក្រោយរបស់លោកប្រេសិតពិសេសនៃអង្គការសហប្រជាជាតិរូបនេះ លោក ស៊ូបេឌី លើកឡើងទៀតថា នៅមានបញ្ហាគួរឱ្យព្រួយបារម្ភខ្លះនៅក្នុងកម្មវិធីនេះ។

លោកបានមានប្រសាសន៍ថា "នៅមានចំណុចគួរឱ្យព្រួយបារម្ភជាច្រើនចំពោះការអនុវត្តន៍កម្មវិធីផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីនេះ ដូចជាកង្វះតម្លាភាព ផលប៉ះពាល់ដល់ជនជាតិដើម ភាគតិច និងអំពីដំណើរការជ្រើសរើសហាគមន៍ឱ្យទទួលប័ណ្ណកម្មសិទ្ធិជាដើម"។

លោកបន្តថា "ខ្ញុំនៅតែមានការព្រួយបារម្ភជាខ្លាំង អំពីវប្បធម៌និទណ្ឌភាពក្នុងប្រទេសកម្ពុជា និងបទឧក្រិដ្ឋជាច្រើនដែលរហូតមកទល់ពេលនេះ គ្មានជនល្មើសណាម្នាក់ត្រូវបាននាំខ្លួនមកផ្តន្ទាទោសឡើយ ។ និទណ្ឌភាពធ្វើឱ្យសាធារណជនបាត់បង់ជំនឿចិត្តលើប្រព័ន្ធយុត្តិធម៌នៅក្នុងប្រទេសនេះ ពោលគឺមិនត្រឹមតែបាត់បង់ទំនុកចិត្តលើតុលាការប៉ុណ្ណោះទេ តែថែមទាំងនគរបាល និងបណ្តាស្ថាប័នអនុវត្តច្បាប់ផ្សេងៗទៀតផងដែរ"។

លោកក៏គូសបញ្ជាក់ដែរថា ការប្រើប្រាស់ច្បាប់ហួសហេតុលើការបណ្តេញចេញកំពុងបង្ខំឱ្យប្រជាពលរដ្ឋធ្លាក់ចូលក្នុងស្ថានភាពខ្លាចខ្លួនឯង។

នៅទីបំផុតលោក ស៊ូបេឌី បានមានប្រសាសន៍ថា លោកភ្ញាក់ផ្អើលចំពោះប្រតិកម្មរបស់រដ្ឋាភិបាលចំពោះអនុសាសន៍របស់លោក។ សេចក្តីរាយការណ៍របស់ក្នុងឆ្នាំនេះស្តីពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា បានបណ្តាលឱ្យមានការឆ្លើយតបទាំងកំហឹងពីសំណាក់លោក ឱម យ៉ិនទៀង ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សរបស់រដ្ឋាភិបាល ដោយបានចោទប្រកាន់លោក ស៊ូបេឌី ថា កំពុងតែធ្វើយុទ្ធនាការឱ្យគណបក្សប្រឆាំងចំណែកលោក ហ៊ុន សែន បានហៅរបាយការណ៍របស់លោកថា "មិនគួរឱ្យជឿ"។

កាលពីថ្ងៃព្រហស្បតិ៍ លោក ហ៊ុន សែន ក៏បានប្រកាសដែរថា លោកមិនជួបជាមួយប្រេសិតសិទ្ធិមនុស្សរូបនេះឡើយ ដោយលោកលើកឡើងថា មិនចាប់អារម្មណ៍នឹងស្តាប់អនុសាសន៍របស់លោកទេ។

លោក ស៊ូបេឌី បានមានប្រសាសន៍ដោយមិនបានលើកឡើងចំៗអំពីការច្រានចោលរបស់លោក ហ៊ុន សែន នូវសំណើរបស់ខ្លួនសុំជួបលោកនោះថា "នៅក្នុងបណ្តាប្រទេសផ្សេងៗការផ្តល់អនុសាសន៍បែបនេះ គេចាត់ទុកថា ជាកិច្ចពិភាក្សាថ្នាក់ជាតិតាមធម្មតា និងជាកិច្ចពិភាក្សាដ៏ស្មោះត្រង់ ប៉ុន្តែការពិភាក្សាប្រកបដោយវិជ្ជាជីវៈនឹងធ្វើឡើងតាមក្រោយ"។

លោកបានមានប្រសាសន៍ក្រោយមកទៀតថា "ជាការពិតខ្ញុំគោរពរដ្ឋាភិបាល និងអធិបតេយ្យភាពរបស់ប្រទេសនេះ ។ អ្វីដែលខ្ញុំកំពុងតែធ្វើក្នុងឋានៈខ្ញុំជាអ្នកជំនាញមួយរូប ដោយជួសមុខឱ្យអង្គការសហប្រជាជាតិ ដើម្បីឆ្លុះបញ្ចាំងពីកាតព្វកិច្ចរបស់កម្ពុជា ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេសនេះ ដែលធានាការពារសិទ្ធិជាមូលដ្ឋាន រួមមានទាំងសេរីភាពជនស៊ីវិល សិទ្ធិនយោបាយសិទ្ធិសេដ្ឋកិច្ច និងសង្គមកិច្ចផងដែរ"។

តទៅទំព័រទី១៤

## UN Envoy Holds Street Meeting With Sonando Sopporters

**The Cambodia Daily**

Ahead of the final press conference of his visit on Friday, the U.N. human rights envoy to Cambodia Surya Subedi, help an impromptumeeting on Phnom Penh's street 302 with more than 300 supporters of jailed radio station owner Mam Sonando, promising to closely monitor the case.

Mr. Sonando's supporters had marched from the Appeal Court, shortly after he was denied bail on Friday, to the U.N. human rights office to seek Mr. Subede's help.

Sentenced in October to 20 years in prison on charges many believe are politically motivated, U.S President Barak Obama has referred to Mr. Sonando,72, as a political prisoner.

Addressing Mr.Sonando Supporters through a public address system, Mr. Subedi said that he regretted not being able to attend the hearing in person, and called the Appeal Court decision "puzzle."

"I am very concerned about this situation and I've made my recommendation at the highest possible level of the government," Mr. Subedi told the crowd who greeted his words with rounds of applause and cheers. He promises that he would continue to monitor Mr. Sonando's case.

"Thank you very much for coming to see me, and I salute to you for your courage of display," Mr. Subedi told the crowd.

Later, at a press conference be fore his departure from Cambodia, Mr. Subedi said that land rights issues, impunity and a shrinking space for freedom of expression are some of major problems that Cambodia face.

Calling the prime minister's recently launched land-titling promgram a "welcome development," which has been implemented since the U.N. envoys' last visit in May, Mr. Subedi added that there are still some concerns with it.

"There are a number of concerns a bout the implementation of this land-titling program, such as a lack of transparency, its impact on indigenous populations and how communities are chosen to be titled," Mr, Subedic said.

"I remain deeply concerned about the culture of impunity in Cambodia, and the long list of crimes for which no one has been brought to justice," Mr. Subedi continued.

"[Impunity] erodes public confidence in the system of justice in the country, not only in the judiciary but also the police and another law enforcement agencies."

He also pointed out that the excessive use of the law on incitement is forcing people into self-censorship.

Finally, Mr. Subedi said was "surprised" by the government's reaction to his recommendations.

His reports this year on the human rights situation in Cambodia have prompted angry responses from Om Yentieng, head of the government's human rights committee, accusing Mr. Subedi of campaigning for the opposition, to Mr. Hun Sen calling his reports "flimsy."

Mr. Hun sen on Thursday also announced that he had not met with the human rights envoy, citing a lack of interest in listening to his advice.

"In other countries, such recommendations are seen as being part of the normal national debate and a frank but professional discusion would have ensued," Mr. Subedi said yeasterday, without directly referring to Mr. Hun Sen's rejection of his requests to meet.

"The focus should remain om the substance of what I am recommending and not on me as a person," he said.

"Of course I fully respect the sovereightly of this country and the comprehence of the government," he added later. "What I'm doing as an expert on behalf of the U.N. is outlining the obligations of Cambodia flowing from the Constitution of the country, which guarantees fundamental rights including civil liberties, political rights, economic and social rights."

With ragard to Mr. Sonando, Mr. Subedi reiterated that he has "intervened at the highest levels" with his concerns, though he declined to e;aborate further.

Stopping short of calling Mr. Sonando and self-exiled opposition party leader Sam Rainsy political prisoners, Mr. Subedi said that he is "treading very carefully" with this term, as there is no international definition for a political prisoner.

"With regard" to finding legal methods designed to bring the leader of the opposition party back to the country, my focus is not on an individual, my focus is on system," Mr. Subedi said. "My recommentdations are there to help the country to hold free, fair and peaceful elections."

Phay Siphan, spokesman for the Council of ministers, said Cambodia is extremely open and welcoming of Mr. Subedi's work in Cambodia. However, his reports only reflect what he sees in his short trips to Cambodia, and not "What is going on" in Cambodia.

"[Mr. Subedi] sees Cambodia as a classroom, but it is not. It is a nation that has been through many challenges and that is learning a lot from its past," Mr. Siphan said. "We don't need a policeman to point fingers and give us lesson."

"We look at him as a partner and we want to improve. But to improve and to make a chang is a completely different approach," he said.

# អ្នកក្រនិងអ្នកមាននៅប្រទេសខ្មែរ ភាគទី២

ដោយ គីម សុស



មុននឹងខ្ញុំជម្រាបតទៅទៀត ខ្ញុំសូមរំលឹកគោលទ្រោះៗអំពីអ្វីដែលបានជម្រាបមកហើយ :

នៅប្រទេសខ្មែរចំនួនប្រាក់ដែលម្នាក់ៗរកបានចេះតែឃ្លាតពីគ្នាឆ្ងាយទៅឆ្ងាយទៅហើយលឿន ឡើងលឿនឡើង។

ដោយសារតែរឿងឃ្លាតគ្នានោះ ប្រទេសខ្មែរអាចនឹងមានបញ្ហាក្នុងសង្គម ។ ព្រោះថាចំនួនអ្នកក្រអាចនឹងមានច្រើនជាងចំនួនអ្នកមានយ៉ាងច្រើនលើសលប់ ។ ភាពក្រីក្រអត់ឃ្លានអាចបណ្តាឱ្យមនុស្សធ្វើអ្វីៗស្ទើរតែគ្រប់បែបយ៉ាង ដូចជាប្រថុយស្លាប់បង្កអំពើហិង្សា លួចប្លន់លះបង់សេចក្តីថ្លៃថ្នូរប្រព្រឹត្តអំពើពុករលួយជាដើម។

ហើយនឹងដើម្បីកាត់បន្ថយភាពក្រីក្រឱ្យបានឆាប់រហ័សបាបសេដ្ឋកិច្ចត្រូវឡើង១០ភាគរយយ៉ាងតិចក្នុងមួយឆ្នាំៗ។

ដូច្នេះមកដល់ពេលនេះ យើងឃើញថាប្រទេសខ្មែរអាចនឹងមានបញ្ហាក្នុងសង្គមដោយសារតែពីរឿងអ្នកក្រនិងអ្នកមាន ។ ហើយបញ្ហានេះអាចបណ្តាលឱ្យប្រទេសខ្មែរកើតមានអំពើបង្ហូរឈមព្រាត់ប្រាសម៉ែឪបងប្អូនដូនតា ដូចកាលជំនាន់ខ្មែរក្រហមបាន ។ ដូច្នេះតើគួរដោះស្រាយយ៉ាងដូចម្តេច។

មុននឹងដោះស្រាយសូមរំលឹកថា ភាពក្រីក្រមាននៅគ្រប់ប្រទេសក្នុងពិភពលោក។ គ្រាន់តែមានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ ចំពោះចំនួនតែប៉ុណ្ណោះទេ។ ឧទាហរណ៍សហរដ្ឋអាមេរិកមានពលរដ្ឋប្រមាណ៣១៣លាននាក់ ចំនួនអ្នកក្រមាន៤៦លាននាក់ ឬ១៥ភាគរយ និងប្រទេសបារាំងពលរដ្ឋប្រមាណ៦៥លាននាក់ចំនួនអ្នកក្រប្រមាណ៩លាននាក់ ឬ១៤ភាគរយ។ ហើយប្រទេសទាំងពីរនេះកំពុងខ្វល់ខ្វាយរកផ្លូវដោះស្រាយបញ្ហាភាពក្រីក្រនេះ។ សូមរំលឹកទៀតថា ចំពោះប្រទេសខ្មែរនៅឆ្នាំ២០០៧ចំនួនអ្នកក្រធ្លាក់មកនៅ៣១ភាគរយនៃប្រជាពលរដ្ឋប្រមាណជាង១៣លាននាក់ មកដល់សព្វថ្ងៃនេះធ្លាក់មកនៅប្រមាណ២៧ភាគរយនៃប្រជាពលរដ្ឋជាង១៤លាននាក់តាមការប៉ាន់ស្មាន។

នៅដើមអត្ថបទនេះ ខ្ញុំបានជម្រាបថាខ្ញុំនឹងដោះស្រាយបញ្ហាភាពក្រីក្រនេះជូន ។ ឥឡូវនេះម្តងទៀត មុននឹងចូលទៅក្នុងការដោះស្រាយយើងគួរយល់អំពីការត្រូវការរបស់ខ្លួនយើងម្នាក់ៗសិន។

មនុស្ស ទោះជាអ្នកមានឬក៏អ្នកក្រក៏ដោយពេញទៅដោយការត្រូវការដែលជាការចាំបាច់ដូចគ្នានេះបើតាមទ្រឹស្តីរបស់អ្នកប្រាជ្ញអាមេរិកាំង ខាងចិត្តសាស្ត្រម្នាក់ឈ្មោះ អេប្រាហាម ហែរលដ៏ម៉ាសស្លូវAbraham Harold Maslow (1908-70) ។ លោកមានប្រសាសន៍ថា មនុស្សជុះជាប់នឹងខ្លួននូវការត្រូវការចាំបាច់ប្រាំប្រភេទ។ ដំបូងបង្អស់ជាចាំបាច់ហើយនឹងជាបន្ទាប់ការត្រូវការមានពីរប្រភេទ :



១គឺ (physiological needs) ការត្រូវការសម្រាប់រស់ គឺជាអ្វីដែលធ្វើឱ្យរស់និងធ្វើឱ្យអាចបណ្តុះបណ្តាលជីវិតតទៅទៀត។

២គឺ (security needs) ការត្រូវការនៃសេចក្តីសុខ គឺជាអ្វីដែលផ្តល់សុវត្ថិភាពដល់ខ្លួន។ សូមបញ្ជាក់ថា ប្រភេទទី១និងទី២នេះជាការត្រូវការដំបូងបង្អស់ហើយជាបន្ទាន់។

៣គឺ (social needs) ការត្រូវការនៃការទទួលស្គាល់ពីសង្គម ដូចជាសេចក្តីស្រឡាញ់រាប់អាននិងសិទ្ធជាម្ចាស់អ្វីមួយ ដូចជាម្ចាស់ការណ៍ជាដើម។ និយាយឱ្យខ្លីមនុស្សចង់ឱ្យគេស្គាល់ចង់ឱ្យគេរាប់អានចង់មានមុខមានមាត់ចង់មានចង់បានជាដើម។

៤ គឺ(self-esteem needs) ការត្រូវការនៃការមានជំនឿនិងទុកចិត្តលើខ្លួនឯង គឺដឹងខ្លួនថាមានគេរាប់អានមានគេគោរព និងមានគេសសើរ។ ជាធម្មតាមនុស្សសប្បាយណាស់កាលណាធ្វើអ្វីមួយដោយខ្លួនឯងបានសម្រេច។

និង៥ ក្រោយបង្អស់ គឺ(self-actualization needs)ការត្រូវការនៃការទទួលសេចក្តីសម្រេច គឺការប្រាថ្នាចង់បានសេចក្តីសម្រេចជោគជ័យសម្រាប់ខ្លួនឯង។

ដូច្នេះ មនុស្ស បើតាមធម្មជាតិទាំងអ្នកមានទាំងអ្នកក្រមានចិត្តដូចគ្នា។

ហើយ បើតាមទ្រឹស្តីនេះ យើងសួរថាតើអ្នកមាននៅឯណា ហើយអ្នកក្រនៅឯណា។ ម្យ៉ាងទៀត បើយើងយកទ្រឹស្តីនេះមកពិចារណាឱ្យជ្រៅទៅហើយយើងងាកទៅមើលមនុស្សនៅប្រទេសខ្មែរ ហើយសង្កេតឱ្យបានជិតដល់មែនទែនទៅយើងអាចចាត់ទុកថា យ៉ាងតិច២៧ភាគរយនៃប្រជាពលរដ្ឋខ្មែរ១៤លាននាក់ធ្លាក់ក្នុងប្រភេទទី១និងទី២នៃការត្រូវការរបស់មនុស្ស ។ នេះបានសេចក្តីថាយ៉ាងតិច២៧ភាគរយ ឬយ៉ាងតិចជិត៤លាននាក់នៃប្រជាពលរដ្ឋ១៤លាននាក់ កំពុងត្រដរដើម្បីរកតែរស់តែប៉ុណ្ណោះនេះបើយើងគិតតាមតួលេខដែលមានតាមផ្លូវការណ៍។ ប៉ុន្តែបើយើងគិតតាមភាពជាក់ស្តែងវិញ យ៉ាងតិច៨០ភាគរយនៃប្រជាពលរដ្ឋនៅប្រទេសខ្មែរ ឬជាង១១លាននាក់ដែលរស់នៅក្រៅក្រុងធំៗហើយពឹងផ្អែកលើរបរកសិកម្មកំពុងត្រដររកតែរស់តែប៉ុណ្ណោះ។ ចំនួនជាង១១លាននាក់ក្នុងចំណោម១៤លាននាក់នេះច្រើនសម្បើមណាស់។ **តទៅទំព័រទី១៣**

# ខ្មែរត្រូវការគណកម្មការបោះឆ្នោតដែលសុច្ចរិត

ដោយ : ម៉ម ឃឹន

ដោយយល់ឃើញថា : ជាង៣៣ឆ្នាំបានកន្លងផុតទៅហើយមាតុប្រទេស និង ប្រជាជាតិខ្មែរ បានត្រូវធ្លាក់ទៅក្នុងកណ្តាប់ដៃក្រុមមេដឹកនាំខ្មែរកុម្មុយនីស្តដែលបានលើកបន្តុបឡើង ដោយកងទ័ពយួនកុម្មុយនីស្ត ហូជីមិញ តាំងពីថ្ងៃទី ៧ ខែមករា ឆ្នាំ ១៩៧៩ មក ។

ពិតមែនតែប្រទេសកម្ពុជាមានសន្ធិសញ្ញាអន្តរជាតិស្តីពីកិច្ចព្រមព្រៀងសន្តិភាពផ្តល់ឯករាជ្យពេញបរិបូរណ៍នាក្រុងហ្សឺណែវប្រទេសស្វីស នាំឆ្នាំ១៩៥៤ ហើយនិងសន្ធិសញ្ញាអន្តរជាតិស្តីពីកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ យ៉ាងនេះក៏ដោយ ក៏គណបក្សប្រជាជនកម្ពុជាគេពុំបានគោរពតាមអត្ថន័យ និងខ្លឹមសារស្មារតីរបស់សន្ធិសញ្ញាអន្តរជាតិនោះឡើយ ។

គណបក្សកាន់អំណាចបានក្តោបក្តាប់អំណាចត្រួតត្រាទាំងស្រុងទៅលើគណកម្មាធិការជាតិរៀបចំការបោះឆ្នោត គជប យ៉ាងពេញទំហឹងដែលជាអំណាចប្រព្រឹត្តផ្ទុយខុសខ្លាំងណាស់ពីច្បាប់រដ្ឋធម្មនុញ្ញប្រជាជាតិខ្មែរជាពិតប្រាកដ ។ ពេលវេលាបានមកដល់ហើយ ពី១អាណត្តិទៅ១អាណត្តិបក្សកាន់អំណាចតែងតែមានចេតនាប៉ងប្រាថ្នាចង់ប្រព្រឹត្តសុទ្ធតែអំពើកោងកាចសាហាវឃោឃៅប្រើអំណាចផ្តាច់ការផ្ទុយគ្នាស្រឡះពីគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្សជាពិតប្រាកដ ។




អាស្រ័យហេតុនេះ នៅក្នុងការបោះឆ្នោតសកលអាណត្តិទី៥ នាឆ្នាំ២០១៣ខាងមុខនេះ យើងជាជាតិខ្មែរត្រូវតែថ្កោលទោសគណកម្មាធិការបក្សរៀបចំការបោះឆ្នោត គជប នេះជាដាច់ខាត ហើយយើងខ្ញុំត្រូវតែតវ៉ាទាមទារ សុំឱ្យកែប្រែសមាសភាពនៃគណកម្មាធិការនេះ ឱ្យបានក្លាយទៅជាគណកម្មការយុត្តិធម៌ត្រឹមត្រូវ និងតម្លាភាពពិតប្រាកដវិញ ដែលនាំឱ្យក្រុមគណបក្សនយោបាយទាំងអស់ទាំងកាន់អំណាចទាំងមិនទាន់កាន់អំណាចអាចទទួលយកបានដោយស្មោះស័គ្រ ទៅតាមស្មារតីសន្ធិសញ្ញាអន្តរជាតិ២៣ តុលា ១៩៩១ និងរដ្ឋធម្មនុញ្ញនិតិរដ្ឋពិតប្រាកដ ។

ដើម្បីជាការចូលរួមផ្តល់ទស្សនៈមតិជួយដោះស្រាយបញ្ហាវិបត្តិដ៏ធំនៃ គជប នេះ ខ្ញុំសូមចូលរួមដោយផ្ញើមកជូនគណបក្សសង្គ្រោះជាតិតាមរយៈកាសែតខ្មែរផុស សូមមេត្តាទទួលយកទៅធ្វើការពិនិត្យពិចារណា និងចាត់ការផ្សព្វផ្សាយតាមការគួរ ។

**ពីក្រុងហ្វីឡាដែលហ្វីយ៉ា ។**

**ត្រូវការលក់ហាងធ្វើក្រចក**
នៅតំបន់ "Providence Plaza Mall"
មានកៅអី៦មានតុធ្វើក្រចក៨ មានបន្ទប់ខ្ញុំដករោម
មានម៉ាស៊ីនបោកហាល បើចង់ទិញពិតប្រាកដ
សូមទូរស័ព្ទ(៦១៧)៥១៥ ៥៣១១
តម្លៃអាចតថ្លៃបាន



BUY RITE Pharmacy

Nhà Thuốc Tây 藥房 ឱសថស្ថាន

267-297-5879

# ឱសថស្ថាន ថាច់ សូមស្វាគមន៍

• ឱសថការី ដាន់ ថាច់ មានសេចក្ដី រីករាយ និងបំរើសុខភាពបងប្អូនក្នុងសហគមន៍ឱ្យបានប្រសើរ ។




1st PRIZE Samsung 32" LED HDTV

រង្វាន់ចាប់ឆ្នោត ខែធ្នូ




2nd PRIZE Samsung 32" LCD HDTV



3rd PRIZE Sony Playstation 3

• ភ្ញៀវដែលមកទិញថ្នាំតាមវេជ្ជបញ្ជាទាំងថ្មីទាំងចាស់ អាចនឹងត្រូវឆ្នោតទទួលរង្វាន់ ដូចរូបខាងក្រោម ថ្ងៃទី៣១ ខែធ្នូ ២០១២
• យើងជូនកូប៉េយដូចអ្នកឯទៀត
• ចុះថ្លៃពិសេសជូនព្រឹទ្ធាចារ្យ ។

• ផ្ញើថ្នាំជូនដល់ផ្ទះដោយឥតគិតថ្លៃ • ទទួលអ៊ិនស្ហ៊ូរិនស៍គ្រប់មុខ • ទទួលបន្តផ្តល់ថ្នាំដែលលោកអ្នកកំពុងប្រើ ទិញមកពីឱសថស្ថានផ្សេងៗ
• តម្លៃថោកៗបំផុត និងមានស្តុកឱសថគ្រប់មុខប្រភេទ • ផ្តល់សេវាដោយរហ័សទាន់ចិត្ត
• មានឱសថវីតាមីន-ឱសថចិនសែ និងឧបករណ៍ព្យាបាលមុខជំងឺ

1337 W.Rockland St.Philadelphia, PA 19141(Corner of Old York Rd & Rockland St.)
Tel: 267-297-5879 Fax: 267-297-5880

# Mekong River

VIETNAMESE RESTAURANT

1120-1124S Front St.,
Philadelphia, PA 19147
(Near Washington Ave. - មានកន្លែងចតឡានត្រឹមត្រូវ
215-467-6100

# GRAND OPENING
# 25-5-2012

មានម្ហូបវៀតណាមគ្រប់មុខ B
ហ្វឺ មី គុយទាវ នំបញ្ចុក បាញ់ហយ Y
បាយ ម្ហូបប្លុស ម្ហូបឆា ម្ហូប សម្រាប់ទទួលជាលក្ខណៈគ្រួសារ O
ទទួលពិធីជប់លៀងជាលក្ខណៈគ្រួសារ ឬជួបជុំមិត្តភក្រ B






មានភោជនីយដ្ឋានទើបបើកនៅក្នុងសហគន៍យើង



ភោជនីយដ្ឋាន អង្គរ
Angkor Restaurant
Angkor Restaurant
Ben city Plaza
ថ្មីនំបញ្ចុកណាំយ៉ា
5520 Whitaker Ave, Unit 7 Philadelphia, Pa 19124 Phone: 215.831.1016
ភោជនីយដ្ឋាន ម្ហូបខ្មែរ ទើបបើកថ្មី !
នៅហ្វីឡាដែលហៀងខាងជើង
សូមអញ្ជើញមកពិសារម្ហូបខ្មែរគ្រប់មុខ ចំអិនដោយចុងភៅខ្មែរស្ទាត់ជំនាញ
នាភោជនីយដ្ឋានធំទូលាយ បំរើម្ហូបខ្មែរពិតប្រាកដដ៏ឈ្ងុយឆ្ងាញ់
អ្នកបំរើភ្ញៀវរួសរាយ មានកន្លែងចតរថយន្តគ្រប់គ្រាន់ !
អាចបញ្ជាឲ្យធ្វើម្ហូបតៅ "មេញ" បានមានម្ហូប អាមេរិកាំង ម្ហូបអាស៊ី ជាដើម
មានធ្វើម្ហូប VG សម្រាប់ អ្នកមិនពិសាសាច់
ម្ហូបដែលចំអិនប្រើពេលយូរ ដូចជាអាម៉ុក សូមបញ្ជាឱ្យបានមុនមួយថ្ងៃ




ហាងមាសរស្មី
SUNSHINE JEWELRY, INC.
215-271-2950
Certified Diamonds & Golds (24K & 18K)
Men & Women Jewelries & Watches
Custom Design & Repairs on Premise
15 Years in Services & Growing Strong
702 Washington Ave. Phila., PA 19147
www.sunshinejewelryonline.com




Phở Hà Saigon
7 days A Week
9am-9pm
Vietnamese Restaurant
B.Y.O.B.
ជាហាងដែលធ្វើ ហ្វើ ឆ្ងាញ់ជាងគេនៅហ្វីឡា-
ដែលហៀងចុងភៅដែលពូកែធ្វើ ហ្វើ និងម្ហូបផ្សេងៗ
ឯទៀត ត្រូវមាត់ភ្ញៀវគ្រប់ៗរូប ឥឡូវនេះមកធ្វើ
ម្ហូបនៅហាង Phở Hà Saigon
យើងខ្ញុំ ហើយធានាថា ម្ហូបអាហារហាង
និងបំរើលោកអ្នកបានយ៉ាងពេញចិត្តគ្រប់ពេលវេលា
VISA
MasterCard
DISCOVER
320 W. Oregon Avenue, Suite 1. Philadelphia, PA 19147
Tel: (215) 389-1002 (Inside Oregon Market)




**តមកពីទំព័រទី ៩**

## អ្នកក្រនិងអ្នកមាននៅប្រទេស....

យើងអាចសួរខ្លួនយើងថាចំនួនជាអ្វី ។ កាលណាយើងនិយាយអំពីចំនួនយើងតែងតែគិតទៅដល់កំឡាំង ។ ដូច្នេះកំឡាំងដែលចេញពីចំនួនមនុស្សជាង១១លាននាក់នេះជារឿងសំខាន់មួយ ហើយរឿងសំខាន់មួយទៀតនៅក្នុងចំណាយននេះគឺចិត្តនិងគំនិត ។ កាលណាយើងនិយាយអំពីចិត្ត និងគំនិតយើងនិយយាអំពីការដឹកនាំ និងការធ្វើអ្វីមួយ ។ ដូច្នេះយើងសួរថាតើចិត្តគំនិតនៃមនុស្សជាង១១លាននាក់នោះកំពុងធ្វើអ្វី ។

តាមបទពិសោធរបស់ខ្ញុំកាលខ្ញុំនៅក្រមែនទៃននោះ គឺនៅពេលដែលខ្ញុំអត់មានខោអាវសមរម្យស្លៀកពាក់ដើរសំបាយគេហូបដើរសំផ្ទះគេនៅខ្ញុំតែងតែមានកង្វល់ក្តៅក្រហាយក្នុងចិត្ត គឺក្តៅក្រហាយខ្វល់ខ្វាយអំពីអត់មានអីដូចគេក្តៅក្រហាយខ្វល់ខ្វាយអំពីចង់ហូបឱ្យបានឆ្ងាញ់ស្លៀកពាក់ឱ្យបានសមរម្យក្តៅក្រហាយអំពីគេមើលងាយ ហើយមានចិត្តច្រណែននឹងគេជាដើម ។ ការរំលឹកដល់ចិត្តខ្ញុំនៅគ្រាមុននោះនេះធ្វើឱ្យខ្ញុំព្រួយបារម្ភ គឺព្រួយបារម្ភថា ទាំងចំនួនជាង១១លាននាក់ ឬមួយភាគធំនៃមនុស្សជាង១១លាននាក់នោះកំពុងគិតដូចខ្ញុំបានគិតដែរនោះ ។

ខ្ញុំសង្ស័យណាស់ ។ ខ្ញុំគិតថាបើមិនទាំងអស់ក៏ភាគច្រើននៃចំនួនជាង១១លាននាក់នោះដែរដែលគិតដូចខ្ញុំបានគិត ។ មូលហេតុដែលធ្វើឱ្យខ្ញុំសង្ស័យយ៉ាងនោះមកអំពីខ្ញុំបានឃើញនឹងភ្នែកខ្ញុំ និងបានឮនឹងត្រចៀកខ្ញុំនៅក្នុងភ្នំពេញក៏ដូចនៅក្រៅភាពតឹងតែងរវាងគ្នានិងគ្នាដោយពាក្យសំដីដោយកាយវិការដោយអំណាចជាដើមកាន់តែខ្លាំងឡើងៗ ។

ដូច្នេះខ្ញុំបារម្ភថា សង្គមខ្មែរនឹងអាចមានបញ្ហានៅពេលណាដែលចិត្តគំនិតរបស់មនុស្សចំនួនជាង១១លាននាក់នេះអាចបង្រួបបង្រួមគ្នាឱ្យទៅជាធ្លុងមួយដើម្បីនឹងផ្តើមចិត្តគំនិតប្រឆាំងនឹងអ្វី



មួយក្នុងសង្គម ។ តែផ្ទុយទៅវិញសង្គមនឹងទទួលនូវសេចក្តីរង់រឿងចំរុងចំរើននៅពេលណាដែលចិត្តគំនិតរបស់កំឡាំងនេះអាចដឹកនាំចំនួនមនុស្សនេះឱ្យទៅជាធ្លុងមួយដើម្បីធ្វើអ្វីមួយដែលសង្គមចង់បាន ។

**កំណត់:** ខ្ញុំសូមស្នេះត្រឹមនេះសិន ។ នៅលើកក្រោយខ្ញុំនឹងលើកមកវែកញែកជូននូវមធ្យោបាយដែលត្រូវធ្វើដើម្បីដើរទៅមុខ ៕






## តមកពីទំព័រទី ៦ លោក ម៉ម សូណង់ដូ ត្រូវបានបដិ...

លោក សុរិយា ស៊ូបេឌី បានថ្លែងដោយប្រើឧគ្ឃោសនសព្ទទៅកាន់ក្រុមអ្នកគាំ ដែលប្រមូលផ្តុំគ្នា នៅខាងក្រៅការិយាល័យអង្គការសហប្រជាជាតិថា "សេចក្តីសម្រេចរបស់តុលាការនៅព្រឹកនេះ គឺធ្វើឱ្យខ្ញុំមិនយល់ទាល់តែសោះ។ នៅក្នុងស្ថានភាពសុខភាព និងអាយុរបស់លោក ខ្ញុំបានរំពឹងថា តុលាការប្រហែលជាដោះលែងលោកឱ្យនៅក្រៅឃុំបណ្តោះអាសន្ន ប៉ុន្តែមិនដូច្នោះឡើយ"។

លោក ស៊ូបេឌី បានទៅសួរសុខទុក្ខលោក ម៉ម សូណង់ដូ នៅក្នុងពន្ធនាគារកាលពីថ្ងៃសុក្រ ហើយបានចំណាយរយៈពេល១ម៉ោង ដើម្បីពិភាក្សាជាមួយលោកអំពីសំណុំរឿងនេះ និងអំពីស្ថានភាពក្នុងពន្ធនាគាររបស់លោក។

អង្គការសិទ្ធិមនុស្សក៏បានសម្តែងការខកចិត្តចំពោះសេចក្តីសម្រេចរបស់តុលាការ ដែលមិនព្រមដោះលែងលោក ម៉ម សូណង់ដូ ឱ្យនៅក្រៅឃុំបណ្តោះអាសន្នដែរ ហើយលើកឡើងថា ហេតុផលដែលតុលាការបានលើកឡើង គឺគ្មានមូលដ្ឋានឡើយ ។

អង្គការសិទ្ធិមនុស្សអាដហុក បានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍មួយថា ការបដិសេធមិនព្រមដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្ន និងបន្តឃុំឃាំងអ្នកយកព័ត៌មានអាយុ៧២ឆ្នាំ និងជាសកម្មជនការពារសិទ្ធិមនុស្សរូបនេះ គឺបង្ហាញឱ្យឃើញថា ប្រព័ន្ធតុលាការប្រទេសកម្ពុជា ទទួលរងឥទ្ធពលនយោបាយ។

គណៈកម្មាធិការប្រព្រឹត្តកម្មនៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជាបានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍ថា "គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា បានលើកឡើងថា សេចក្តីសម្រេចនេះខ្វះហេតុផលផ្លូវច្បាប់ ដោយមិនបានពិចារណាលើកសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីលោក ម៉ម សូណង់ដូ ឡើយ"។

គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា បានបន្តថា "យើងព្រួយបារម្ភអំពីការជ្រៀតជ្រែកខាងនយោបាយចូលទៅក្នុងប្រព័ន្ធតុលាការនៅក្នុងសំណុំរឿងនេះ"៕

## តមកពីទំព័រទី ៧ លោក ស៊ូបេឌី ជួបជាមួយអ្នកគាំទ្រ...

ទាក់ទិននិងរឿងក្តីលោក ម៉ម សូណង់ដូ លោក ស៊ូបេឌី បានគូសបញ្ជាក់ជាថ្មីថា លោក "បានយកចិត្តទុកដាក់ខ្លាំងណាស់"ដោយសារការព្រួយបារម្ភរបស់លោក ប៉ុន្តែលោកមិនបានបញ្ជាក់លម្អិតបន្ថែមទៀតទេ។

ដោយស្នើរតែហៅលោក ម៉ម សូណង់ដូ និងលោក សម រង្ស៊ី មេដឹកនាំគណបក្សសមរង្ស៊ី ដែលនិរទេសខ្លួននៅក្រៅប្រទេសថា ជាអ្នកទោសនយោបាយទៅហើយនោះ លោក ស៊ូបេឌី បានថ្លែងថា "លោកប្រយ័ត្នប្រយែងណាស់"ជាមួយនឹងការប្រើពាក្យនេះ គ្មាននិយមន័យអន្តរជាតិពិតប្រាកដសម្រាប់ពាក្យថា អ្នកទោសនយោបាយនេះទេ។

លោកស៊ូបេឌី មានប្រសាសន៍ថា "ទាក់ទិននឹងការស្វែងរកមធ្យោបាយដោះស្រាយតាមផ្លូវ ដើម្បីឱ្យមេដឹកនាំគណបក្សប្រឆាំងរូបនេះ បានវិលត្រឡប់មកកាន់ប្រទេសវិញ ការផ្តោតជាសំខាន់របស់ខ្ញុំមិនមែនទៅលើបុគ្គលម្នាក់ទេ គឺជាប្រព័ន្ធការងារតែម្តង។ អនុសាសន៍របស់ខ្ញុំមាននៅទីនេះស្រាប់ ដើម្បីជួយប្រទេសនេះ ឱ្យបានរៀបចំការបោះឆ្នោតដោយសេរី យុត្តិធម៌ និងគ្មានអំពើហិង្សា"។

លោក ផៃ ស៊ីផាន អ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រីមានប្រសាសន៍ថា ប្រទេសកម្ពុជា ពិតជាបើកចំហ និងស្វាគមន៍ចំពោះកិច្ចការរបស់លោក ស៊ូបេឌី នៅក្នុងប្រទេសកម្ពុជា ។ តែទោះជាយ៉ាងណារបាយការណ៍របស់លោក គ្រាន់តែឆ្លុះបញ្ចាំងពីអ្វីដែលលោកបានមើលឃើញអំឡុងដំណើរទស្សនកិច្ចរយៈពេលខ្លីមកកាន់កម្ពុជា ប៉ុណ្ណោះ មិនមែនមើលឃើញពី"អ្វីដែលកំពុងកើតមាន" នៅក្នុងប្រទេសកម្ពុជាឡើយ។

លោកបានបន្តថា "លោក ស៊ូបេឌី ចាត់ទុកកម្ពុជា ជាថ្នាក់រៀន ប៉ុន្តែវាមិនមែនឡើយ។ វាជាប្រទេសមួយ ដែលបានឆ្លងកាត់ឧបសគ្គជាច្រើន ហើយដែលកំពុងតែសិក្សាអំពីអតីតកាលរបស់ខ្លួន ។ យើងមិនត្រូវការនគរបាលយកដៃចង្អុលប្រាប់យើង និងផ្តល់មេរៀនដល់យើងនោះទេ"។

លោកបានលើកឡើងទៀតថា"យើងចាត់ទុកគាត់ជាដៃគូ ហើយយើងចង់បានកាន់តែល្អ និងដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរ គឺជាវិធីដោះស្រាយផ្សេងគ្នា"៕

Add some Sparkle to any room of the house this season & shop at...

CONSIGNMENT CORNER

ហាងដែលលោកអ្នកអាចមកទិញរបស់ថ្មី ឬរបស់ប្រើបន្ត
ទិញបានរបស់ប្រើប្រាស់ល្អ ហើយតម្លៃថោក

- Furniture, Bureaus
- Kitchen Sets
- Lots of Small Table
- Mirrors
- Dishes Sets
- Glass Ware
- Cake Plates

- មានបរិក្ខាការិយាល័យ
- គ្រឿងប្រើប្រាស់ក្នុងជើងក្រាន
- តុតូចៗមួយចំនួន
- កញ្ចក់តាំងជញ្ជាំង
- សិតចាន កែវ ទទួលភ្ញៀវ
- ថាសដាក់នំ... ។ល។

- Vintage Ornaments
- Byers Choice
- Lenox-Waterford
- Hummels
- Jewelries
- Sleds
- Lots of Sparkle
- Ceramic Trees
- Outdoor Ornaments

•គ្រឿងតាំងលម្អក្នុងផ្ទះគ្រប់យ៉ាង •ដើមឈើលម្អធ្វើពីចាន ឬកែវ
•គ្រឿងតាំងលម្អក្រៅផ្ទះពេលបុណ្យទាន

យើងមានវត្ថុ
តាំងលម្អគ្រប់ផ្នុន
សំរាប់តាំងតុ ពិធីបុណ្យ
ឱ្យមានសោភ័ណភាព
និងភាពអ៊ឹកធឹក

មានលក់បញ្ចុះថ្លៃច្រើន
រហូតដល់ថ្ងៃអាទិត្យ
ទី២៣ធ្នូ នៅហាងទាំង៣

8,000 SQ Ft.
978-251-7130
Open Wed-Sun.

បើកហាងពីថ្ងៃពុធដល់អាទិត្យ

17 Groton Road – Route 40. North Chelmsford, MA
Check us out at: www.consignmentcorner.net

New Asia Restaurant

343 Market Street. Lowell, MA 01852
(Corner of the New Asia Market) 978-441-6363






ភោជនីយដ្ឋានទើបបើកថ្មី! សូមអញ្ជើញមកពិសារម្ហូបអាហារគេជាតិឆ្ងាញ់
ធ្វើដោយចុងភៅចំណាន មានបរិភោគស្រស់ តម្លៃថោកសមរម្យ




បំរើដោយម្ហូបខ្មែរ_ថៃ_ឡាវ_វៀតណាម និងចិន



ម្ហូបពិសេស!
- សម្លរឆ្នាំងភ្លើង
- គោឡើងភ្នំ
- ភ្លាអង់ស្ងារ( តាមរបៀបបារាំង)
- ភ្លាត្រីសាល់ម៉ុន
- អាំងត្រីសាល់ម៉ុនស្វាយខ្ចី

*បញ្ញាបុខម្ហូប!
*ប្រពិសារ "ប៊ុហ្វេថ្ងៃត្រង់" ពីម៉ោង១១ដល់ម៉ោង៣ តម្លៃតែ $7.50

Special Lunch Buffet (11-3 p.m)
7.50 per person




Open 7 Days a Week
9 a.m. – 9 p.m.

# លក់ហាងពាណិជ្ជកម្ម

**អាចបើកលក់គ្រឿងទេសធ្វើម្ហូបខ្មែរ និងហាងធ្វើ**
**នំចាខ្វៃ នៅឡូវែលរដ្ឋម៉ាសាឈូសែត**

**OPEN CAMBODIAN GROCERY/**
**BAKERY IN LOWELL, MA**

**មានគ្រឿងបរិក្ខារាប់ទាំងចង្ក្រាន និងម៉ាស៊ីនធ្វើនំបុ័ងផង**

(EQUIPMENT INCLUDED KITCHEN AND BAKE MACHINE)
WELL ESTABLISHED BUSINESS
FREE FRONT PARKINGS








**ASKING PRICE: $85,000**
**CALL (978) 996-7259 FOR SHOWINGS.**

## Business for sale

**LOCATES IN PAILIN PLAZA**
**BUSY TRAFFIC AREA**

**នៅក្នុង"ប៉ៃលិនប្លាសា"**
**...តំបន់មានមនុស្សចេញចូលច្រើន**

716 Middlesex St.
Lowell, MA




**មានលក់ ស្បង់ ចីវរ សំរាប់ព្រះសង្ឃ**

មានលក់សាច់ស្រស់ ត្រីស្រស់ ក្តាម ក្តាម មានបន្លែស្រស់
គ្រប់មុខ ពិសេសមានបន្លែតម្រូវម្ហូបខ្មែរ-លាវ មានផ្លែឈើអាស៊ី
គ្រប់យ៉ាង ដូចជាផ្លែម្កាក់ សាវម៉ាវ ផ្លែស្វាយ ផ្លែជំពូរ ខ្មោរ ទាបបារាំង
ទាបស្ងិត ផ្លែមង្ឃុត ផ្លែមាន ផ្លែស្រកានាគ ។ល។មានលក់ម្ហូបស្ងួត
ក្នុងកញ្ចប់ នៅខាងក្រៅ ឬក្នុងទូទឹកកកគ្រប់មុខ មានលក់របស់របរ
ប្រើប្រាស់ក្នុងផ្ទះ ។

**ពិសេស:** មានជ្រូកខ្វៃ ទាខ្វៃ មាន់ស្ងោដាក់ខ្ទឹម មាន់ទឹកស៊ីអ៊ីវ
ត្រីចៀន ត្រីខ ទឹកអំពៅក្បៀប នំបាវនំបាំង
បង្អែមញ៉ាំកំសាន្តផ្សេងៗ ។

**មានកាសែតខ្មែរ**
**រៀងរាល់ពីរអាទិត្យ**







**Open: Mon-Sat:**
**9am-8pm**
**Sun:9am-7pm**

475 Flatbush Avenue. Harford, CT 06106
Tel:(860)953-5458 -Fax:(860)953-5462

# សហគមន៍ខ្មែរកោតសរសើរថ្នាក់ដឹកនាំខ្លួន

**ខ្មែរផុស ស.រ.អា**

**លីន :** នៅភោជនីយដ្ឋាន ប៊ុហ្វេ មួយនៃទីក្រុងលីន សហគមន៍ខ្មែរនាទីក្រុង លីនបានធ្វើកិច្ចជប់លៀងប្រចាំឆ្នាំមួយ ដើម្បីអរគុណដល់អ្នកដែលបានធ្វើសេចក្តីល្អប្រសើរប្រចាំឆ្នាំដល់សហគមន៍ខ្លួន ក្រោមកិច្ចដឹកនាំរបស់គ្រគង្វាល ហូ សាន នៃវិហារគ្រីស្តសាសនា ខ្មែរនៅលីនឹងហ្សៀល កាលពីថ្ងៃសៅរ៍ទី១៣ ខែធ្នូ ឆ្នាំ២០១២ ។



លោក ហុង ណេត និងគ្រួសារ



លោក គីរី រដ្ឋ សាំង

មនុស្សម្នាប្រមាណ ១៥០នាក់ ទាំងចាស់ទាំងក្មេងបានរីករាយទទួលភោជនាហារអាស៊ីច្រើនសិបមុខ ក្រោមអធិដ្ឋាននៃព្រះគ្រីស្តនឹងក្រោមភាពរីករាយនៃការជួបជុំបងប្អូនមិត្តភក្តិជាពិសេស នាំគ្នាអបអរ នឹងការថ្លែងការកោតសរសើរដល់មនុស្សសំខាន់បីរូប ដែលបានក្លាយជាថ្នាក់ដឹកនាំនៃសហគមន៍ ។



គ្រូគង្វាល ហូ សាន

ហូ សាន បានទទួលស្គាល់ស្នាដៃនៃអ្នកទទួលរង្វាន់ដំបូង គឺលោក ហុង ណេត ជាអ្នកបង្ហាញផ្លូវថា"ខ្មែរមានសេចក្តីក្លាយហាននឹងសមត្ថភាពដូចគេឯងក្នុងការជាប់ឈ្មោះ ជា តំណាងរាស្ត្រក្នុងក្រុង ហើយបំរើសហគមន៍យ៉ាងគួរឱ្យកោតសរសើរ" ។

អ្នកទទួលសញ្ញាប័ត្របន្ទាប់ គឺលោក សាំង គីរីរដ្ឋ ដែលបំរើការងារ សាលាក្រុងបានត្រូវគេទទួលស្គាល់គ្រប់គ្នាថា "ជួយដល់ពលរដ្ឋដោយពុំមានគិតពី ពេលវេលារបស់ ខ្លួន ហើយជួយដល់ថ្នាក់ ដឹកនាំបរទេសឱ្យស្គាល់នឹងពីសហគមន៍ខ្មែររឹតតែ ប្រសើរបាន" រីឯអ្នកទីបីជាយុវនារីម្នាក់ឈ្មោះ សូភី លី ដែលលះបង់ការងារដ៏សំខាន់ងាយស្រួល ដើម្បីឱ្យបានមកនៅជិតទីប្រជុំសហគមន៍ខ្មែរ ដើម្បីនាងយកចំណេះដឹងពេលវេលាគេបំរើសហគមន៍ឱ្យបានហ្មត់ចត់" ។



នាង សុភី លី ទទួលប័ណ្ណកោតសរសើរពីចៅហ្វាយក្រុងលីន អ្នកស្រី ហ្វានណាឌី



អ្នកទាំងបីបានទទួលប័ណ្ណកោតសរសើរពីមន្ត្រីជាន់ខ្ពស់របស់ក្រុង គឺអ្នកស្រី ហ្វាណាក្ទិន កិណ្ណីឌី នឹងពីតំណាងសហគមន៍ ក្រោមស្នូរទះដៃដ៏រំពងនៃអ្នកចូលរួម ។

នាង សុវណ្ណ មនី ហៅមុំជាសមាជិកនៃព្រះវិហារគ្រីស្តម្នាក់រស់នៅ លីន និយាយថា នាងមានសេចក្តីរីករាយនឹងឃើញការទទួលស្គាល់មនុស្សដែលមានស្នាដៃជួយយកអាសារមនុស្សក្នុងសហគមន៍ ហើយនាងក៏បានស្គាល់ថា អ្នកដែលទទួលប័ណ្ណកោតសរសើរនោះដែរថា ជាការសមរម្យពេកណាស់" នាងបន្តថា"សហគមន៍ ខ្មែរច្រើនឮថា មានទាស់ទែងគ្នាមានការប្រើហិង្សា ច្រើន តែនៅលីនខ្ញុំយល់ថា មានដែរតែតិចតួចទេ" ។



សុវណ្ណ មុនី

រាត្រីអរគុណប្រចាំឆ្នាំនេះ មានការបញ្ចាំងវីដេអូពីសកម្មភាពសហគមន៍នឹងការបង្ហាញស្នាដៃសិល្បៈដូរតន្ត្រីសរសើរព្រះទៀតផង ៕

តមកពីទំព័រទី ៤ ភិក្ខុ លួន សាវ៉ាត...

ប្រគេនជូននូវប័ណ្ណសរសើរសំរាប់"ការ លះបង់មិនស្តាយអាយុជីវិតក្នុងការការពារសិទ្ធិមនុស្ស" ។

គួសបញ្ជាក់ផងដែរថា សកម្មភាពរបស់ព្រះអង្គ គឺផ្តោតទៅលើកិច្ចការ តស៊ូមតិ តស៊ូយុត្តិធម៌ ដើម្បីសិទ្ធិសេរីភាព រីក៏ជនទាំងឡាយណា ដែលប្រឈមមុខ ចំពោះហានិភ័យ និងទាក់ទងទៅនឹងបញ្ហាគ្រោះថ្នាក់ផ្សេងៗ ។

NEW ENGLAND INSTITUTE OF HVAC, Inc.
វិទ្យាស្ថានញូអិនគ្លិនជំនាញខាងបង្រៀនពី
ម៉ាស៊ីនកំដៅ, ម៉ាស៊ីនត្រជាក់ និងទូទឹកកក
ថ្នាក់រៀនពេលថ្ងៃ និងពេលល្ងាច និងផ្តើមឆាប់ៗនេះ
បំពេញការសិក្សាបច្ចេកទេសខាងម៉ាស៊ីនត្រជាក់
ម៉ាស៊ីនកំដៅ ទូទឹកកក HVAC គឺសិក្សា
តែរយៈពេល១៣សប្តាហ៍
• សិក្សាដោយពិសោធន៍ផ្ទាល់ដៃ • ជួយរកការងារធ្វើ
• ផ្តល់សម្ភារៈឱ្យ • ថ្នាក់រៀនសិស្សតិច
• GI Bill Education Benefits Approved
• Section 30 Approved



NATE Certifications,
EPA Testing,
OSHA, and Financing Available
to those who qualify
គឺជាប្រភពសម្រាប់ថាមពលបៃតង
Call for details: 978.735.4979
NEW ENGLAND INSTITUTE OF HVAC, INC
240 Smith St., Lowell, MA 01851
www.newenglandhvac.com

ក្រុមហ៊ុនទេសចរណ៍អន្តរជាតិ អង្គរ
(Since 1991)
ក្រុមហ៊ុនទេសចរណ៍អន្តរជាតិ-អង្គរ
Angkor International Travel Agency



World Wide Travel & Tour Service
Cambodia - Vietnam - Laos - Thailand
ទទួលផ្ញើរប្រាក់ទៅស្រុកខ្មែរ សេវាអន្តោប្រវេសន៍
សេវាលិខិតឆ្លងដែន កក់សណ្ឋាគារ ឬជួលឡាន
USA
4931 N. Old York Rd.
Philadelphia, Pa 19141
Tel: (215) 329-2036
Fax: (215) 329-7176
General Manager NARY PO
angkortravelphilly@yahoo.com
Cambodia Office: Victory Travel (Skin Belle)
No 57B, Eo Street 205 Touls Svay Prey 2.
Phnom Penh, Cambodia.
Ms. Chenda: 023-221069 * 012-851575
Or Mr. Sin Po: 012 429407 * 011-541111.
SERVING SINGAPOR, EVA AIR, CHINA, ASIANA KOREAN AILINES

តមកពីទំព័រទី ១

# ប្រទេសកម្ពុជាក្នុងតំបន់...

-កោះ Spratly, ជាកោះសំបូរទៅដោយប្រេង និងឧស្ម័នដែលជាកម្មវត្ថុនៃការប្តឹងតវ៉ាទាមទារជាកម្មសិទ្ធិរបស់ប្រទេសខ្លួនជាមួយប្រទេសហ្វីលីពីន ប្រទេសវៀតណាម ប្រទេសម៉ាឡេស៊ី និង ប្រទេសប្រ៊ុយណេ។

-កោះ Paracel, ស្ថិតក្រោមការគ្រប់គ្រងរបស់ប្រទេសចិនចាប់តាំងពីសង្គ្រាមលោកលើកទីពីរ បច្ចុប្បន្នកំពុងប្រឈមមុខជាមួយប្រទេសវៀតណាម និងកោះតៃវ៉ាន់ ដែលបានអះអាងថា ជាកោះរបស់ខ្លួន។

-កោះ Senkaku ស្ថិតនៅសមុទ្រចិនខាងកើតកំពុងមានជម្លោះយ៉ាងតឹងតែងជាមួយប្រទេសជប៉ុន ។

-The Aksai Chin តំបន់ Kashmiren ប្រទេសឥណ្ឌាប៉ែកខាងជើងនៃតំបន់នេះស្ថិតក្រោមការត្រួតត្រារបស់ប្រទេសចិន ហើយបច្ចុប្បន្នប្រទេសឥណ្ឌាអះអាងថា ជាកម្មសិទ្ធិរបស់ប្រទេសខ្លួន ។ រដ្ឋ Arunachal Pradesh ដែលជារដ្ឋមួយស្ថិតនៅខាងជើងភាគខាងកើតរបស់ប្រទេសឥណ្ឌាត្រូវបានទាមទារកាន់កាប់ដោយប្រទេសចិន។ ប្រទេសចិនបានរាប់បញ្ចូល Arunachal Pradesh ជាផ្នែកមួយនៃទឹកដីរបស់ប្រទេសខ្លួន។

- រដ្ឋាភិបាលចិនបានចេញនូវលិខិតឆ្លងដែនថ្មីដែលនៅកន្លងនោះរួមមានផែនទីប្រទេសចិន ដែលបានគូសពង្រីកបូរណភាពទឹកដីរបស់ខ្លួនទៅលើតំបន់ដែលទាមទារដោយប្រទេសហ្វីលីពីន ប្រទេសវៀតណាម ប្រទេសប្រ៊ុយណេ ប្រទេសឥណ្ឌា កោះតៃវ៉ាន់ និងប្រទេសម៉ាឡេស៊ី ដែលបាននាំឱ្យកើតនូវវិបត្តិការទូតប្រចាំតំបន់។

-ប្រទេសចិនបានដាក់ពង្រាយកងកម្លាំងប្រដាប់អាវុធបន្ថែមនៅតាមជាយសមុទ្រ ដើម្បីយាមល្បាត និងស៊ើបអង្កេតទៅលើនាវាបើកបរលើផ្ទៃសមុទ្រដែលកំពុងមានជម្លោះស្ថិតនៅសមុទ្រចិនខាងត្បូង (យោងតាម "សម្លេងប្រទេសរុស្ស៊ី" ផ្សាយចេញថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១២) ។

**ការកើនឡើងយ៉ាងលឿននៃកងទ័ពចិន :**

ជាច្រើនឆ្នាំមកនេះរដ្ឋាភិបាលបានបើកកម្មវិធីហ្វឹកហាត់យ៉ាងទូលំទូលាយជាមួយសព្វាវុធទំនើប ដើម្បីពង្រឹងសមត្ថភាពកងទ័ពនិងកងនាវីរបស់ខ្លួន ។

កញ្ចប់ថវិការសំរាប់ចំណាយផ្នែកកងទ័ពបានកើនឡើងប្រមាណ១២.៧ភាគរយ ក្នុងឆ្នាំ ២០១១ ដែលស្មើនឹង៦៧០.២កោតយ័ន (៨០.៥កោតយូរ៉ូ) ។ តួលេខនេះបានកើនឡើងពីរខ្ទង់ច្រើនជាងកំណើនផលិតផលសរុបក្នុងស្រុក (GDP) នៃប្រទេសចិនដែលបានកើនឡើងត្រឹមតែ +៩.២ ភាគរយនៅឆ្នាំ២០១១ប៉ុណ្ណោះ។

នាវាដឹកយន្តហោះដំបូងរបស់ចិន "Liaoning" បានបើកប្រតិបត្តិការជាផ្លូវការចាប់តាំងពីថ្ងៃ ២៤ ខែកញ្ញា ឆ្នាំ២០១២ មានផ្ទុកយន្តហោះប្រយុទ្ធធុនធ្ងន់ J-១៥។

របាយការណ៍ប្រចាំឆ្នាំនៃនាយកដ្ឋានការពារប្រទេសសហរដ្ឋអាមេរិកនៅឆ្នាំ២០១០ ដែលមានចំណងជើងថា "ការអភិវឌ្ឍន៍លើវិស័យយោធា និងសន្តិសុខរបស់សាធារណរដ្ឋប្រជាមានិតចិន" បានថ្លែងថា ប្រទេសចិននឹងមានលទ្ធភាពដាក់ឱ្យដំណើរការនាវាផ្ទុកយន្តហោះពីរទៅបីបន្ថែមទៀត នៅក្នុងរយៈពេលដប់ឆ្នាំខាងមុខ។ (បានឃើញ"របាយការណ៍អាកាសចរណ៍" ចាប់ពីថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១២) ។

ចាប់តាំងពីឆ្នាំ២០០០ មកទល់ពេលនេះ កងទ័ពរំដោះប្រជាជនដែលហៅកាត់ថា (PLA) មានសមាជិកចំនួន២,៣លាននាក់: នេះជាកងទ័ពឈានមុខគេបង្អស់របស់ពិភពលោក។



សម្ព័ន្ធមិត្តសំខាន់ៗរបស់ចិននៅអាស៊ីរួមមាន ប្រទេសកូរ៉េខាងជើង និងប្រទេសកម្ពុជាដែលប្រកាន់នូវគោលការណ៍តែមួយ (យោង "Xinhua" ផ្សាយថ្ងៃទី១១ ខែឧសភា ឆ្នាំ ២០១០)។

**ការផ្លាស់ប្តូរកងកម្លាំងរបស់សហរដ្ឋអាមេរិកនៅអាស៊ី**

នៅពេលដែលប្រទេសកម្ពុជាកំពុងតែមានទំនាក់ទំនងស្អិតល្មួតជាមួយប្រទេសចិន ចំណែកឯសហរដ្ឋអាមេរិកបានបំពាក់ផ្នែកការទូតប្រចាំប្រទេសមួយចំនួនដែលជាដៃគូរសំខាន់ៗដូចជា :

-ប្រទេសថៃជាសម្ព័ន្ធមិត្តដ៏យូរអង្វែង ទោះបីជាមានពេលខ្លះទំនាក់ទំនងមានបញ្ហារកាំរកូសក៏ដោយ។

-ប្រជាជនភូមាដែលទើបបានគេទទួលស្គាល់ឱ្យនៅក្នុងរង្វង់ប្រជាជាតិពិភពលោក ។ ប្រទេសភូមាក៏មានការសើរើភាពជាប់អន្ទាក់ជាមួយប្រទេសចិនដែលធ្លាប់ជាសម្ព័ន្ធមិត្តមានជាច្រើនទសវត្សមកហើយ ។

ឆ្នាំមុនសហរដ្ឋអាមេរិកបានពង្រឹងបន្ថែមកងកម្លាំងទាហានរបស់ពួកគេ: សហរដ្ឋអាមេរិកបានបន្ថែមកងទ័ពជើងទឹកពីលើចំនួន២៥០នាក់ទៀតបញ្ជូនមកប្រទេសអូស្ត្រាលី រួចហើយនឹងមានគំរោងសាងសង់មូលដ្ឋានទាហានជើងទឹកចំនួន៦០ភាគរយបន្ថែមទៀតមកកាន់តំបន់អាស៊ីនៅឆ្នាំ២០២០។

ទោះបីជារដ្ឋាភិបាលចិនធ្វើអ្វីគ្រប់យ៉ាងដើម្បីបណ្តេញស.រ.អាឱ្យទៅឆ្ងាយក៏ដោយ ក៏ស.រ.អា នៅតែព្យាយាមបន្តខិតរិតតែជិតដដែល។

នៅខែវិច្ឆិកា ប្រធានាធិបតីអាមេរិកលោក Barak Obama បានប្រកាសថា សហរដ្ឋអាមេរិកនឹងពង្រឹងកំលាំងយោធារបស់ខ្លួនដែលមានមូលដ្ឋាននៅប្រទេសអូស្ត្រាលី ចំណែកឯរដ្ឋាភិបាលចិនបានចាត់ទុកការសំរេចរបស់អាមេរិកថា ជាសង្គ្រាមត្រជាក់។

ទីក្រុងវ៉ាស៊ីនតោនកំពុងមានគំរោងដាក់កប៉ាល់ចំបាំងប្រចាំការនៅប្រទេសសឹង្ហបុរី ដែលកំពង់ផែរបស់ប្រទេសនេះ ត្រូវបានគេរៀបចំតម្រូវឱ្យសមស្របតាមទំហំនៃការចុះចតរបស់យន្តហោះចំបាំងដែលប្រើដោយថាមពលនុយក្លេអ៊ែ ។ និងតម្រូវតាមការបង្កើតចំនួនទ័ពនៅហ្វីលីពីន និងថៃឡង់ត៍ ។ ព្រឹទ្ធសភាសហរដ្ឋអាមេរិកបានអនុម័តជាឯកច្ឆន្ទថា "សហរដ្ឋអាមេរិកបានអះអាងជាថ្មីអំពីការគាំទ្រសម្ព័ន្ធមិត្តជប៉ុន នៅក្នុងជម្លោះរវាងប្រទេសជប៉ុនជាមួយប្រទេសចិននៅលើដែនដីកោះនៃសមុទ្រចិនខាងកើត"។

សហរដ្ឋអាមេរិកមានថវិការយ៉ាងច្រើនសន្ធឹកសន្ធាប់ជាងគេនៅលើពិភពលោកទៅលើវិស័យយោធា: ៧៦៨កោត (៥៥២,១១យូរ៉ូ) ក្នុងឆ្នាំ២០១១ សូមអាន "Le Monde" ថ្ងៃ១៧ខែកុម្ភៈ ឆ្នាំ២០១២)។

សម្ព័ន្ធមិត្តសំខាន់ៗរបស់សហរដ្ឋអាមេរិកក្នុងអាស៊ីរួមមាន: ប្រទេសជប៉ុន កោះតៃវ៉ាន់ ប្រទេសកូរ៉េខាងត្បូង ប្រទេសអូស្ត្រាលី និងប្រទេសសឹង្ហបុរី។

សម្ព័ន្ធមិត្តសក្តានុពលរួមមានប្រទេសថៃ និងប្រទេសម៉ាឡេស៊ី។

**ប្រទេសកម្ពុជានៅក្នុងតំបន់ខ្យល់ព្យុះ**

កម្ពុជាបានធ្វើជាប្រធាននៃកិច្ចប្រជុំអាស៊ានលើកទី២១ ដែលប្រារព្ធធ្វើនៅភ្នំពេញថ្ងៃទី១៨ ដល់ទី២០ ខែវិច្ឆិកា ឆ្នាំ ២០១២ កម្ពុជាជាម្ចាស់ផ្ទះដោយស្វាគមន៍តំណាងអាស៊ានចំនួន១០ប្រទេសរួមមាន ប្រទេសកម្ពុជា ប្រទេសភូមា ប្រទេសប្រ៊ុយណេ ប្រទេសឥណ្ឌូណេស៊ី ប្រទេសឡាវ ប្រទេសម៉ាឡេស៊ី ប្រទេសហ្វីលីពីន ប្រទេសសឹង្ហបុរី ប្រទេសថៃឡង់ និងប្រទេសវៀតណាម។

ក្នុងឱកាសនោះដែរយើងក៏បានឃើញគណៈប្រតិភូសំខាន់ៗដែលបានអញ្ជើញមកដូចជា នាយករដ្ឋមន្ត្រីចិន លោក Wen Jiabiao នាយករដ្ឋមន្ត្រីឥណ្ឌាលោក Manmohan Singh ប្រធានាធិបតីកូរ៉េខាងត្បូងលោក Lee Myung-bak ប្រធានាធិបតីសហរដ្ឋអាមេរិកលោក Barack Obama ។

ទើបតែជាប់ឆ្នោតថ្មីៗ លោក បារ៉ាក់អូបាម៉ាបានមកទស្សនកិច្ចនៅប្រទេសម្ពុជា រយៈពេលពីរថ្ងៃគឺថ្ងៃទី១៨ និង ទី១៩ ខែវិច្ឆិកា ឆ្នាំ២០១២នេះពីទៅប្រទេសភូមា និងប្រទេសថៃ។

ដំណើរទស្សនកិច្ចដែលជាការកត់សម្គាល់ពីសារសំខាន់យុទ្ធសាស្ត្រសម្រាប់តំបន់ ស.រ.អា ទៅលើសារតាថ្មីនៃការពង្រីកឥទ្ធិពលរបស់ចិនឈានទៅកាន់មហាអំណាចពិភពលោក។

ទំនាក់ទំនងនៃភាពលំអៀងរបស់ប្រទេសកម្ពុជាទៅលើប្រទេសចិន បានប្រែក្លាយទៅជាសំពាធនិងផលវិបាកដែលបង្កដោយសហរដ្ឋអាមេរិក និងសម្ព័ន្ធមិត្តនាពេលខាងមុខគឺ :

-នៅពេលដែលប្រទេសចិនបានបង្ហូតទង់ជាតិឱ្យនៅត្រឹមពាក់កណ្តាលដងដើម្បីគោរពវិញ្ញាណក្ខន្ធព្រះមហាក្សត្របរោត្តមសីហនុនៅរាជធានីទីក្រុងប៉េកាំងថ្ងៃទី១៥ ខែតុលា ឆ្នាំ ២០១២ ប្រធានាធិបតីអាមេរិកលោកបារ៉ាក់អូបាម៉ាបានមានវត្តមាននៅទីក្រុងភ្នំពេញ នៅថ្ងៃទី១៨ និង ១៩ ខែវិច្ឆិកា ឆ្នាំ ២០១២ ដើម្បីចូលរួមប្រជុំអាស៊ានលើកទី២១ ដោយលោកបារ៉ាក់អូបាម៉ាមិនបានចូលរាជវាំងដើម្បីគោរពវិញ្ញាណក្ខន្ធនិងចូលគាល់ព្រះមហាក្សត្រឡើយ។

នៅក្នុងអាល់ប៊ុមរូបថត៤១នៃដំណើរទស្សនកិច្ចរបស់លោក បារ៉ាក់អូបាម៉ា ទៅប្រទេសថៃ-ភូមា និង

តទៅទំព័រទី ២០

# ប្រវត្តិរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ រ.ជ.រ.ប.ខ លោកតា សឺន សាន


លោក ម៉ម យឹន

ដោយ : ម៉ម យឹន

(តពីលេខមុន)

**សាមគ្គីភាពជិតស្និទ រវាងពលរដ្ឋក្នុងស្រុក និង កងទ័ពស្នេហាជាតិ**



ពីមួយថ្ងៃទៅមួយថ្ងៃ នៅក្នុងផ្ទៃនៃប្រទេសខ្មែរក្តីនៅតាមមូលដ្ឋាន និង បញ្ជាការដ្ឋានកងកម្លាំង កជរបខ ធំៗក្តីបានពង្រឹង ធមិសាមគ្គីគ្នា និងរួបរួមគ្នាបំពេញភារកិច្ចយ៉ាង យកចិត្តទុកដាក់ និងមមាញឹកយ៉ាងខ្លាំងទាំងយប់ ទាំងថ្ងៃទៅតាមមុខនាទីរបស់ខ្លួនរៀងៗខ្លួន ។ ជាពិសេសខាងផ្នែកផ្សព្វផ្សាយព័ត៌មាន និងគោល ការណ៍នយោបាយរបស់រណសិរ្សជាតិ និងកង កម្លាំងទ័ពជាតិឱ្យបានដឹងទៅដល់ប្រជាពលរដ្ឋ ខ្មែរទូទៅ និងទៅដល់ប្រជាពលរដ្ឋនៅលើពិភព លោកទាំងអស់ ដើម្បីជួយគាំទ្រ និងផ្តល់ជំនួយ ជាគ្រឿងអាវុធ គ្រាប់រំសេវ ស្បៀងអាហារ ថ្នាំ ពេទ្យ និងសម្ភារៈសឹកសំខាន់ៗចាំបាច់ក្នុងការធ្វើ ប្រតិបត្តិការវាយប្រយុទ្ធ ។

ស្របពេលជាមួយគ្នាស្ថានីយ៍វិទ្យុផ្សាយសម្លេង ដែលរំដោះប្រជាពលរដ្ឋខ្មែរទៅជាមួយផងដែរ ។

ចាប់តាំងពីពេលដែលប្រើយុទ្ធសាស្ត្រថ្មីនេះ មកសកម្មភាពប្រតិបត្តិការណ៍សឹកវាយប្រយុទ្ធទៅ លើកងទ័ពខ្មែរ-យួន បានប្រព្រឹត្តទៅជាប់រហូត កង កម្លាំង កជរបខ ទាំងកងៗបានបញ្ជូនចូលទៅក្នុង ផ្ទៃប្រទេសបន្ថែមទៀតជារៀងរាល់ថ្ងៃ ។ ពីព្រោះ នៅក្នុងភូមិ-ស្រុក) និងក្រុងមានក្រុមសម្ងាត់បាន ជ្រៀតចូលទៅរស់នៅបានយ៉ាងស្ងប់សុខ ហើយ ប្រជាពលរដ្ឋក៏បានដឹងនឹងយល់អំពីគោលការណ៍

គោលបំណងនៃរណសិរ្សជាតិ និងកងកម្លាំង កជរបខ ដែលចង់រំដោះប្រទេស និងសង្គ្រោះបំរើ ការពារប្រជាពលរដ្ឋខ្មែរ ឱ្យបានឯករាជ្យ និងសុខ សន្តិភាពឡើងវិញ ។

ចំណែកភ្នាក់ងារយកព័ត៌មានអន្តរជាតិច្រើន តែងតែតាមដានសកម្មភាពប្រតិបត្តិការសឹកនេះ កាន់តែច្រើនឡើងៗជាលំដាប់លំដោយដែរ ។

**សាមគ្គីភាពជិតស្និទ្ធរវាងពលរដ្ឋក្នុងស្រុក និង កងទ័ពស្នេហាជាតិ**

ពី១ថ្ងៃទៅ១ថ្ងៃ នៅក្នុងផ្ទៃនៃប្រទេសខ្មែរក្តី នៅតាមមូលដ្ឋាន និងបញ្ជាការដ្ឋានកងកម្លាំង កជរបខ ធំៗក្តី បានពង្រឹង សាមគ្គីគ្នា និងរួបរួម គ្នាបំពេញភារកិច្ចយ៉ាងយកចិត្តទុកដាក់ និងមមាញឹក យ៉ាងខ្លាំង ទាំងយប់ទាំងថ្ងៃទៅតាមមុខនាទី របស់ខ្លួនរៀងៗខ្លួន ។ ជាពិសេសខាងផ្នែកផ្សព្វផ្សាយ ព័ត៌មាន និងគោលការណ៍នយោបាយរបស់រណសិរ្ស ជាតិ និងកងកម្លាំងទ័ពជាតិឱ្យបានដឹងទៅដល់ ប្រជាពលរដ្ឋខ្មែរទូទៅ និងទៅដល់ប្រជាពលរដ្ឋ នៅលើពិភពលោកទាំងអស់ ដើម្បីជួយគាំទ្រ និង ផ្តល់ជំនួយជាគ្រឿងអាវុធគ្រាប់រំសេវស្បៀង អាហារ ថ្នាំពេទ្យ និងសម្ភារៈសឹកសំខាន់ៗ ចាំបាច់ ក្នុងការធ្វើប្រតិបត្តិការណ៍វាយប្រយុទ្ធ ។

ស្របពេលជាមួយគ្នានោះ ស្ថានីយ៍វិទ្យុផ្សាយ សំឡេង ដែលមានឈ្មោះ វិទ្យុសំឡេងខ្មែរ បាន រៀបចំបង្កើតឡើងបើកផ្សាយចេញពីដើមឆ្នាំ១៩ ៨១ នៅក្នុងមូលដ្ឋានអគ្គសេនាធិការ នៃកងកម្លាំង ទ័ព កជរបខ ។ ដូច្នេះស្ថានីយ៍វិទ្យុផ្សាយសំឡេង នេះ បានធ្វើសកម្មភាពយ៉ាងខ្លាំងក្លាទាំងយប់ទាំង ថ្ងៃដែរ ក្រោមកិច្ចសហការណ៍គ្នាយ៉ាងជិតស្និទ្ធ របស់បងប្អូនប្រជាពលរដ្ឋខ្មែរ ខាងក្នុងស្រុក និង ក្រៅប្រទេស ដែលស្ម័គ្រចិត្តចូលជួយដោយទឹក ចិត្តអង់អាចក្លាហាន ដូចជាលោកបណ្ឌិត ព្រហ្ម អ៊ឹម លោកបណ្ឌិត ឡៅ ម៉ុងហៃ លោកបណ្ឌិត ហ៊ុំងគុនថុន លោកបណ្ឌិត ពាងម៉េត ហ្គាហ្វា លោក ប៉ុល ហំ លោក តាន់គីមថៃ លោកស្រី លី ប៉េងគុន លោកស្រី ចាន់សុជាតិ ជាដើម និងមាន អស់លោកអ្នកសំខាន់ៗជាច្រើនរូបទៀត សូម អភ័យទោសដែលពុំបានរាប់ឈ្មោះ ។

អស់លោកអ្នកសំខាន់ៗទាំងនោះ បានជួយ យ៉ាងពេញទំហឹង ក្នុងការតំឡើងស្ថានីយ៍វិទ្យុ ជា បណ្តាញសារព័ត៌មានទាក់ទងទៅប្រទេសនានា ពេញពិភពលោកទាំងមូល មិនថាតែប្រទេស លោកសេរីទេ សូម្បីតែប្រទេសលោកកុម្មុយនីស្ត ក៏រណសិរ្សជាតិព្យាយាមទាក់ទងជាមួយទៀង ទាត់ដែរ ។ ដូច្នេះប្រទេសដែលផ្តល់ជំនួយខាងការ ផ្សព្វផ្សាយនេះ ខ្លាំងក្លាជាងគេ គឺសហរដ្ឋអាមេរិក ប្រទេសជប៉ុន ប្រទេសសិង្ហបុរី និងប្រទេសថៃឡង់ ដូចជាជួយផ្តល់គ្រឿងវិទ្យុផ្សាយសំឡេងគ្រប់ធុន ជួយតំឡើងទាំងស្ថានីយ៍ (**មានតលេខក្រោយ**)


ក្រុមហ៊ុនធានារ៉ាប់រងដែលបាន
បំរើសង្គម២២ឆ្នាំហើយ
CONWAY INSURANCE



For over 23 years, **Conway Insurance Agency** has been your community's one-stop provider of quality insurance services in New England.
We are a **full-service agency** offering:

- Personal Insurance
  - Autos
  - Homes
  - Apartments
  - Jewelry
  - Fine arts
  - Collectibles
- Business Insurance
  - Property
  - Liability
  - Professional Liability
  - Worker's compensation
  - Bonds
  - Auto, Garage keepers.
  - Disability and life insurance (individual and group products)
  - Other specialty programs

ក្រុមហ៊ុនធានារ៉ាប់រង ផ្ទះ រថយន្ត មុខរបរ និងសុខភាព

**យើងនិយាយភាសាខ្មែរ**

CONWAY INSURANCE AGENCY

P.O. Box 1744
77 E. Merrimack Street
Lowell, MA 01853
Tel: 978-454-5054
Fax: 978-453-2480

**www.ConwayInsurance.com**

សូមសួររក Philip Muth, Philip@ConwayInsurance.com

East Coast Center
for Plastic & Laser Surgery

Mai Ngoc Tran, M.S., Skin Care Specialist
Joseph A. Russo, M.D. F.A.C.S
Plastic & Reconstructive Surgeon
www.eastcoastsurgery.com




**ហាងកែសម្ផស្សយើងខ្ញុំមានទទួលកែសម្ផស្ស បុរស_ស្ត្រី ដែលមាន អាការៈដូចជា: ខ្លាញ់ក្បាលពោះ ពង្រីកសុដន់ឲ្យធំ កែខ្ទប់ច្រមុះ កែត្របកភ្នែក កែមុខស្រស់ស្អាត...។ល។ និង។ល។ និងមានលក់ឧបករណ៍កែសម្ផស្សផ្សេងៗជាច្រើនទៀត**

381 West Broadway South Boston, MA 02127
**(617) 464 - 0001**

# វិធីបន្ធូរនិងលំហែកាយនិងចិត្ត និងក្រេបជញ្ជក់រស់ជាតិជីវិត

# Method how to relax mind and body in order to enjoy life.



**តពីលេខមុន**

ជីវិតជាក់ស្តែង។ បើអ្នកមានការហាត់ហ្វឹកហ្វឺនខាងសមាធិផងនោះ អ្នកនឹងមានជំនួយមួយយ៉ាងធំគាំទ្រដល់ការហាត់តម្រង់សតិបើកទូលាយ នេះ។

ខ្ញុំសូមឆ្លៀតឳកាសនេះ អានជូនពាក្យស្លោកបូរាណមួយប្លែក ហើយមានន័យយ៉ាងជ្រាលជ្រៅសំរាប់ស្វែងយល់អំពីអាថិកំបាំងនៃជីវិតមនុស្សនេះ។ ពាក្យស្លោកនេះគឺ : "ពុំមានបរមសុខនៅលើរបស់ជាក់ស្តែងឡើយ នៅលើរបស់មានកំណត់ឡើយ នៅលើរបស់មានព្រំដែនឡើយ។ បរមសុខមានតែលើរបស់ណាដែលមានលក្ខណៈធំទូលំទូលាយជាអនន្តដែលគ្មានព្រំដែនដែលធំធេងវាស់ស្ទង់ពុំបាន ។ យើងត្រូវតែតួចចិត្តចង់យល់របស់ជាអនន្តនេះ។ សូមអានពាក្យស្លោកនេះ ជាភាសារអង្គ្លេសៈ There is no true bliss in anything finite. The infinite alone is bliss. This infinite, however, We must desire to understand" ។ តើអ្នកធ្លាប់ដែលសង្កេតបាតុភូតមួយដែលផុះឡើងពីក្នុងខ្លួនអ្នកមក ? បាតុភូតនេះមានសភាពជាកម្លាំងជំរុញពីក្នុងមកមានសភាពជានិន្នាការពង្រីកខ្លួនធំឡើងៗ មាននិន្នាការជាការដុះដាលសាយភាយធំឡើងៗ Expansion tendency ។ បើរៀនសូត្រមានបំណងចង់ឱ្យចេះច្រើនឡើងៗ ។ បើស្វែងរកទ្រព្យសម្បត្តិ គឺចង់មានបានច្រើនឡើងៗជាសម្បត្តិមហាសាល។ នៅក្នុងសង្គមចង់ឱ្យឈ្មោះល្បីសុសសាយលើសកលលោក ។ ម្យ៉ាងទៀត ពេលមនុស្សពេញវ័យហាមពលតណ្ហាផុះដុតរោលពីក្នុងខ្លួនមកជាធម្មជាតិតណ្ហានេះបណ្តាលឱ្យយើងមានចំណង់ចង់ពង្រីកគ្រួសារចង់បានគូរស្រករមានប្តីប្រពន្ធបែកសាយកូនពូនជាចៅឡើង។ ដោយឡែកក្នុងពិភពចិត្តមនុស្សៗក៏មាននិន្នាការជាធម្មជាតិ ដូចខាងលើនេះដែរ។ ក្នុងប្រវត្តិមនុស្សជាតិមនុស្សមានចេតនាចង់ស្វែងយល់ពិភពចិត្តដែលមានរូបជាក់ស្តែង ។ លំហូរគំនិត អារម្មណ៍ ការប្រតិកម្ម ម៉េម៉ូរី ការចងចាំប្រវត្តិពីអតីតកាល បុគ្គល CONSCIOUS UNCONSCIOUS SUBCONSCIOUS ។ល។ ហើយមនុស្សពុំនៅទ្រឹងតែកន្លែងនោះឡើយ តែកន្លែងមានរូបភាពនោះឡើយ មនុស្សមាននិន្នាការឈានបន្តទៅរុករកស្វែងយល់ពិភពហួសអំពីកាយ និងចិត្តពិភពគ្មានរូប The invisible world beyond mind and body / matter ស្វែងយល់អំពីសច្ចៈធម៌ អំពីធម្មជាតិពិតរបស់ខ្លួន អំពីចិត្តបរិសុទ្ធ អំពីចរិកសតិដឹង ដែលជាទីរួចរំដោះ ជាព្រះនិព្វាន ជាឧត្តគតិដ៏ខ្ពង់ខ្ពស់បំផុត និងជាទីបរមសុខរបស់មនុស្សជាតិដូចដែលខ្ញុំបានជំរាបក្នុងអត្ថបទដ៏វែងខាងលើនេះស្រាប់។ តើអ្នកជ្រាបអំពីព្រឹត្តិការណ៍ទាំងនេះឬទេ ?

បូរាណបានកំណត់បែងចែកមនុស្សពីប្រភេទ :

មនុស្សទី១ គេយល់ថា ជីវិតមានតែរូបកាយ និងចិត្តនេះជីវិតមានតែលោកសំភារៈប៉ុណ្ណោះ។ មនុស្សបែបនេះ គេរស់នៅយកគំនិតជាធំយកលំហូរគំនិតជាធំ គេចាត់ទុកខ្លួនគេជាគំនិតនេះ គេធ្វើតាមតែបញ្ជារបស់គំនិតពីក្នុងមក ( Man identifies himself with his body, his mind, his thought, his emotions) គេគិតថាគេជាអ្នកបង្កើតលំហូរគំនិតទាំងនោះឡើង តែតាមធាតុពិតគំនិតទាំងនោះផុះចេញពីម៉េម៉ូរី ឬក្រោមពីការចងចាំដែលសង្គមមនុស្សបានបំពាក់ឱ្យយើងតៗគ្នាពីជំនាន់មួយទៅជំនាន់មួយ។ មនុស្សប្រភេទនេះគេរស់នៅដូចទីងមោងក្រោមឥទ្ធិពលខ្សែញាក់របស់អ្នកដ៏ទៃសង្គមមនុស្សតែប៉ុណ្ណោះ។ មនុស្សប្រភេទនេះគេរស់នៅពឹងផ្អែកតែលើគំនិតទស្សនៈអ្នកដ៏ទៃ ពុំមានជំរើសខ្លួនឯងឡើយ។

មនុស្សទី២ គឺជាប្រភេទមនុស្សយល់ដឹងថា ខ្លួនគេពុំមែនជាលំហូរគំនិតនេះទេ គេជាមនុស្សដែលមានវត្តមាននៅពីក្រោយបាតុភូតលំហូរគំនិតទាំងនោះ នៅពីក្រោយមនោសញ្ចេតនា អារម្មណ៍ ការប្រតិកម្មនោះៗ ។ មនុស្សប្រភេទទី២នេះ គេទទួលស្គាល់ថា គេមានរូបកាយនេះ មានលំហូរគំនិតនេះ គេមានអារម្មណ៍នេះ ប៉ុន្តែគេពុំមែនជារបស់ទាំងនោះឡើយ គេជាអ្នកប្រើប្រាស់របស់ទាំងនោះ។ គេឋិតនៅក្នុងគំនិតផង និងនៅពីលើដាច់ផុតពីគំនិតផង។ គេមានសិទ្ធនឹងប្រើប្រាស់ជ្រើសរើសគំនិតណាល្អៗ ហើយអាចបោះបង់គំនិតណាពុំត្រឹមត្រូវ ។ លំហូរគំនិតទាំងនោះ គ្រាន់តែជាអ្នកផ្តល់យោបល់ប៉ុណ្ណោះ ខ្លួនគេមានអំណាចជាអ្នកសំរេច will power ។ មនុស្សទី២នេះ មានសមត្ថភាពអាចកាន់កាប់វាសនារបស់គេបានទាំងស្រុង ពីព្រោះ (1) គំនិតដែលផុះឡើងក្នុងចិត្តនេះ គ្រាន់តែជាយោបល់ប៉ុណ្ណោះ គេមានសិទ្ធិជ្រើសរើសនឹងសំរេចជាប្រយោជន៍សំរាប់ខ្លួនគេ និងអ្នកដ៏ទៃ។ (2)គេពុំត្រឹមតែរង់ចាំទទួលគំនិតនានាពីក្នុងមកតែប៉ុណ្ណោះទេ គេថែមទាំងមានអំណាចនឹងបង្កើតគំនិតល្អ គំនិតវិជ្ជមាន គំនិតជាប្រយោជន៍ គំនិតប្រកបដោយសីលធម៌។ ជនទី២នេះ អាចនឹងតម្រង់វាសនាខ្លួនឯងបានគេលែងឋិតនៅក្រោមឥទ្ធិពលកម្មផលពីអតីតកាលទាំងស្រុងទៀតហើយ។ ចំណែកឯមនុស្សប្រភេទទី១ លំហូរគំនិត គឺជាបញ្ជាផ្តាច់ការពីក្នុងមកដែលជាប្រភពនៃសោកនាដ្ឋកម្មលើភពផែនដីយើងនេះ។ ចូរអ្នកពិនិត្យខ្លួនអ្នកផ្ទាល់ទៅមើល តើអ្នកជាប្រភេទមនុស្សបែបណា? ពាក្យពេជដែលខ្ញុំរៀបរាប់មកនេះមានលក្ខណៈល្អិតសុខុមនាំឱ្យមនុស្សសាមញ្ញពិបាកយល់ណាស់។ ចូលអ្នកព្យាយាមអានឱ្យបានច្រើនសារនោះអ្នកនឹងទទួលជ្រួតជ្រាបនឹងយល់ដឹងជាពុំខានឡើយ។

សូមចងចាំថា បើអ្នកគ្រាន់តែដឹង និងយល់អំពីទ្រឹស្តីវិធីបន្ធូរលំហែកាយនិងចិត្តដូចរៀបរាប់ខាងលើនេះហើយក៏ដោយអ្នកអាចនឹងទទួលផលដ៏រាបណាអ្នកអនុវត្តដោយផ្ទាល់ ។ **តទៅលេខក្រោយ**


# ផ្សារអាតាឡង់ទិក

## Atlantic Market

135 main St, Danbury, CT 06810

**203-830-3068**




ផ្សារនេះមានម្ចាស់ឈ្មោះ **ជាន់ ស៊ីខ** បើកលក់ដូរតាំងពី១០ឆ្នាំមកហើយ ជាពិសេសយើងជាអ្នកលក់ត្រីស្រស់ៗនៅក្នុងក្រុង ។ បន្ថែមពីលើលក់ត្រីស្រស់ យើងមានលក់បន្លែសម្រាប់ម្ហូបអាស៊ី ។

**យើងទទួលយក :** American Express -លុយសុទ្ធ -Debit card -Master Card -Visa

**បើកទ្វារ :** ថ្ងៃច័ន្ទ ម៉ោង ៩:៣០ព្រឹក ដល់៧ល្ងាច/ ថ្ងៃអង្គារ៍ ដល់ថ្ងៃសៅរ៍ ៩:៣០ដល់៨ល្ងាច/ ថ្ងៃអាទិត្យ ៩:៣០-៧:០០

**ទីធ្លាចតរថយន្តឥតគិតថ្លៃ**








# តើអំណោយអ្វីដ៏ល្អបំផុត ដែលអ្នកអាចឲ្យទៅកូនរបស់អ្នក នៅរដូវនេះ?

## សេចក្ដីសន្យាថាគេនឹងមានការថែទាំសុខភាព នៅពេលគេត្រូវការវា។

ការធានារ៉ាប់រងសុខភាព ដោយឥតគិតថ្លៃ
ឬថោកថ្លៃ សំរាប់ក្មេងៗ និងក្មេងជំទង់ៗ
ដែលពុំបានធានារ៉ាប់រង។



ដាក់ពាក្យសុំនៅថ្ងៃនេះ តាមលេខ

**1-888-888-1211**

TTY 1-877-454-8477

chip Pennsylvania's Children's Health Insurance Program

www.chipcoverspakids.com

KidzPARTNERS HEALTH PARTNERS

www.kidzpartners.com

## ANGKOR AUTO SERVICE,INC.

## ហាងជួសជុលរថយន្ត "អង្គរ"

**Free Estimate**

**Auto Body and Maintenance**



BODY WORKS

Auto glass and windshields

Auto Frame Straightening and Painting

មានបទពិសោធន៍២០ឆ្នាំ ជាជាងរថយន្តមាន សញ្ញាប័ត្រវាយតម្លៃការងារដោយឥតយកថ្លៃ ហើយយើងជួយសន្សំប្រាក់តម្លៃបន្ថយរបស់ អិនស៊ូរិនបានផង យើងផ្ដល់សេវាគ្រប់យ៉ាង :

ENGINE AND TRANSIMISSION SERVICES

State Inspection
Check Engine Light Diagnostic
Timing Belt Services
Complete Tune Up:
-Brake -Muffler -Struts
-Water Pump -A/C
-Bearing Services



From the moment you get into car accident, we will take care of you from towing to calling your insurance, and to get a rental car for you. With Angkor Auto, you can be worried free.

4835 N. 16th Street. Philadelphia, PA 19141

Tel : (215) 455-7810 / Ricky : (215) 485-1425



## ហាងខ្មែរជួសជុលរថយន្ត

បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ

# Rathe´s Auto Service

State and Emission Inspaction General Repairs and Maintenance




MON-SAT, 8:30AM-5:30PM
SUN. EMERGENCY ONLY

- ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
- មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
- មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ
- មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : - ដូរប្រេងកំរិត ៥ ក្វាត $22
- INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់ -មានជូនប័ណ្ណពិសេស សំរាប់ដូរប្រេងចុះថ្លៃពាក់កណ្ដាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
- តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត ។
- ប្ដេជាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ។ ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬ ធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL : (215) 329-2418
Fax : (215) 329-2419. Rath CELL : (215) 431-6376



"She tells me all the time
I'm so happy.
She loves being home with us."

CAREGIVER™
HOMES

Caregiver Homes™ helps elders and individuals with disabilities enjoy a high quality of life at home

- **Pays & trains** a full-time, live-in caregiver
- Provides **professional support** from a dedicated nurse and care manager
- Helps you find & **access all necessary services**

For more information, call **866.797.2333** or visit our website.
**WWW.CAREGIVERHOMES.COM**

- BEER
- WINE
- COFFEE

# SOC TRANG
VIETNAMESE RESTAURANT

413 736-9999




113 VERMONT STREET. SPRINGFIELD, MA 01108

យើងមានសេចក្តីរីករាយ និងសូមអញ្ជើញលោកអ្នកព្រមទាំងគ្រួសារ អញ្ជើញមកពិសារម្ហូបពិសេស ចំអិនដោយចុងភៅដ៏ជំនាញរបស់យើង និងលំហែរកាយនៅសាលពិសារភោជនាហារ ដែលរៀបចំយ៉ាងប្រណិតសំរាប់ទទួលលោកអ្នក ។



**ACCEPTING NEW PARTY BOOKINGS, ASSOCIATION MEETINGS, BIRTHDAYS ETC**
**200 PEOPLE CAPACITY.**

**ម្ហូបពិសេស**

- មានហ្វើ -មានគុយទាវ -មានបាយស្រូប មានគ្រឿងក្លែម
- មានបំរើភេសជ្ជៈស្រាបៀ និងភេសជ្ជៈមានសុរាតិច

**ទទួលកក់ពិធីជប់លៀង ឬ ធ្វើការប្រជុំរបស់សមាគម ឬ ធ្វើបុណ្យខួបកំណើត...**
**(ឱ្យខ្ចីសាលមិនគិតថ្លៃ _យកតែថ្លៃបំរើម្ហូប)**

**Open Monday-Sunday**
**9 a.m. – 9 p.m.**
**Closed Thursdays**

**SPECIALS:**
*PHO * NOODLES *RICE COMBO
*SERVE BEER, LIGHT ALCOHOL DRINKS.

# ឧទ្យានជាតិ



# ព្រះសុរាម្រិតកុសុមៈគីរីរម្យ

ឧទ្យានជាតិគីរីរម្យ គឺជារមណីយដ្ឋានទេសចរណ៍ធម្មជាតិមួយដ៏ល្បីក្នុងចំណោមរមណីយដ្ឋានឧទ្យានជាតិធំ៧ផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា ហើយគីរីរម្យក៏ជារមណីយដ្ឋានមានកេរ្តិ៍ឈ្មោះល្បីល្បាញខ្លាំងកាលពីក្នុងសម័យសង្គមរាស្ត្រនិយម ។ រមណីយដ្ឋានឧទ្យានជាតិនេះសម្បូរទៅដោយទេសភាពល្អប្រណីតលំអដោយដើមស្រល់ដុះពីធម្មជាតិនៅលើខ្ពង់រាបគីរីរម្យជ្រោះទឹកធ្លាក់ជាច្រើនអន្លើ និងសត្វម្រឹគម្រឹគាជាច្រើនអម្បូររស់នៅទីនោះ ។





●●● ឧទ្យានជាតិគីរីរម្យគ្របដណ្តប់លើផ្ទៃដីប្រមាណ៨.៤០១ហិកតា និងស្ថិតនៅលើខ្ពង់រាបដែលមានរយៈកម្ពស់ចាប់ពី៣០០ទៅ១០០០ម៉ែត្រពីនីវ៉ូសមុទ្រ ។ រមណីយដ្ឋានគីរីរម្យ គឺជាតំបន់ឧទ្យានធម្មជាតិដ៏ធំដែលស្ថិតនៅជិតរាជធានីភ្នំពេញជាងគេ ហើយតាំងនៅទិសខាងត្បូងឆៀងខាងលិច (និរតីទិស) នៃរាជធានីប្រទេសកម្ពុជា ។ ពីក្រុងភ្នំពេញគេអាចធ្វើដំណើរទៅទស្សនាតំបន់គីរីរម្យបានយ៉ាងងាយស្រួលតាមរយៈផ្លូវជាតិលេខ៤ដូចទៅកាន់ក្រុងព្រះសីហនុដែរ ប៉ុន្តែដល់បង្គោលគីឡូម៉ែត្រលេខ៨៧ត្រង់មុំផ្លូវបំបែកត្រែងត្រយឹងគេនឹងឃើញមានផ្លូវបំបែកខាងស្តាំដៃមួយឆ្ពោះទៅកាន់តំបន់ គីរីរម្យដែលមានចម្ងាយផ្លូវ២៧គ.ម ក្នុងរយៈចម្ងាយផ្លូវ១០គ.ម ដំបូងគឺជាផ្លូវរាបស្មើ និង១៧គ.ម បន្ទាប់គឺជាផ្លូវឡើងខ្ពង់រាប និងភ្នំ ។ រមណីយដ្ឋាននេះមានចម្ងាយពីរាជធានីភ្នំពេញ ១១៤គ.ម និង១៤៧គ.ម ពីក្រុងព្រះសីហនុ ឬមានចម្ងាយ៤៤គ.ម ពីទីរួមខេត្តកំពង់ស្ពឺ ។

ព្រៃធម្មជាតិនៅតំបន់គីរីរម្យរួមមានប្រភេទព្រៃស្រល់សុទ្ធភាគច្រើន និងព្រៃឈើតំបន់ត្រូពិកជាច្រើនប្រភេទទៀត ។ ព្រៃស្រល់ធម្មជាតិ គឺជាចំណុចពិសេសរបស់រមណីយដ្ឋាននេះ ហើយក៏ជាព្រៃស្រល់បម្រុងទុកធំជាងគេបំផុតនៅប្រទេសកម្ពុជាផងដែរ គេបែងចែកព្រៃនៅតំបន់នោះជាប្រភេទព្រៃស្រល់ចម្រុះ ឬព្រៃ Dipterocarpaceas និងព្រៃដាំស្លឹកធំ Gallery Forest ដុះនៅតាមមាត់អូរជ្រោះស្ទឹង និងព្រៃមួយប្រភេទទៀត គឺជាព្រៃស្រោងសើមដែលសម្បូរទៅដោយជីវសាស្ត្រចម្រុះនៅទីនោះផងដែរ ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាក៏បានចុះបញ្ជីរមណីយដ្ឋានគីរីរម្យជា "ឧទ្យានជាតិព្រះសុរាម្រិត" ដែលមានផ្ទៃដី៣៥០០០ហិកតា តាមព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុវរ្ម័នចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ។ ហើយឧទ្យានជាតិនេះបានបើកសម្ពោធឲ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៩៩៥ រហូតមកដល់បច្ចុប្បន្ននេះ ។ នៅរៀងរាល់ចុងសប្តាហ៍មានភ្ញៀវទេសចរពីក្រុងភ្នំពេញជាច្រើនតែងនាំគ្នាទៅសម្រាកលំហែកាយកម្សាន្តលេងជាមួយនឹងសម្រស់ធម្មជាតិដ៏ស្រស់ត្រកាលនៅទីនោះ ។ អាហារក្នុងស្រុកជាច្រើនប្រភេទត្រូវបានអ្នកស្រុកលក់សម្រាប់ភ្ញៀវជាតិ និងជនបរទេសផងដែរ ហើយក៏មានធ្វើម្ហូបអាហារក្តៅភ្លាមៗលក់នៅតាមរោងឬក៏នៅតាមមាត់ស្ទឹង និងអូរផងដែរ ដែលមានតម្លៃសមរម្យអាចទទួលយកបាន ។

នៅក្នុងតំបន់ឧទ្យានជាតិគីរីរម្យបច្ចុប្បន្នមានតំបន់ទេសចរណ៍សំខាន់ៗសម្រាប់ភ្ញៀវជាតិ និងអន្តរជាតិចូលទស្សនា និងលេងកម្សាន្តសប្បាយជាច្រើន ក្នុងនោះមានរមណីយដ្ឋានទឹកជ្រោះភ្នំដំណាក់ចាស់ ដំណាក់ថ្មី តំបន់ស្រះស្រង់ តំបន់ទឹកធ្លាក់ ជ្រោះអូរតាហ៊ុយ តំបន់ចំការតែ ភ្នំថ្មដា និងតំបន់ល្អាងភ្នំ ។

ក្រៅពីតំបន់ទេសចរណ៍សំខាន់ៗខាងលើនេះ តំបន់ឧទ្យានជាតិគីរីរម្យនៅមានតំបន់សំខាន់ៗជាច្រើនទៀត ដែលជារមណីយដ្ឋានទេសចរណ៍ធម្មជាតិមានទឹកធ្លាក់ដ៏ខ្ពស់អមដោយធម្មជាតិស្រស់ត្រកាលនោះ គឺរមណីយដ្ឋានទឹកធ្លាក់អូរប្រាក ឬហៅថា ទឹកធ្លាក់ចំបក់ដែលតាំងនៅផ្នែកខាងជើងនៃតំបន់ឧទ្យានជាតិគីរីរម្យស្ថិតនៅក្នុងភូមិសាស្ត្រឃុំចំបក់ស្រុកភ្នំស្រួចខេត្តកំពង់ស្ពឺ ។

គីរីរម្យជាតំបន់ខ្ពង់រាប និងជាប្រជុំភ្នំតូចធំជាច្រើនដែលគ្របដណ្តប់ដោយព្រៃឈើមានពណ៌បៃតងគ្រប់រដូវកាលមានបរិមាណទឹកភ្លៀងខ្ពស់ប្រហាក់ប្រហែលតំបន់មាត់សមុទ្រផងដែរ ជាកត្តាបង្កើតឲ្យមានជ្រោះ និងអូរមានទឹកហូរធ្លាក់ជាច្រើននៅតាមចន្លោះភ្នំនីមួយៗផ្តល់ជារមណីយដ្ឋានទឹកធ្លាក់ជាច្រើននៅរាយពាសពេញតំបន់នោះ ។ តំបន់គីរីរម្យគឺជាប្រភពទឹកសម្រាប់បង្កើតជាវារីអគ្គិសនីដំបូងគេនៅប្រទេសកម្ពុជាតាំងពីទសវត្សរ៍ឆ្នាំ១៩៦០ គេអាចនាំយកចរន្តថាមពលអគ្គិសនីទាំងនោះមកផ្គត់ផ្គង់នៅរាជធានីភ្នំពេញនាពេលបច្ចុប្បន្ន ៕





